مدرسة اهل البيت

# សាលា អាស់លុល-បៃត៍

## សៀវភៅ ហ្វីកោះហ៍ ថ្នាក់ទី ៤

(អាយុ ៨-៩ ឆ្នាំ)

រ៉សូលុលឡោះហ៍ﷺមានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជា ជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ ........................................ ៥

មេរៀនទី ២ - អ៊្វស្ទ្រូល អ៊ុដ្វឌ្វីន - អារម្ភកថា .................... ១១

មេរៀនទី ៣ - តៅហ្វ៊ីដ្វ ........................................ ១៥

មេរៀនទី ៤ - អ្រុដ្វាឡាត្ត់ ........................................ ២០

មេរៀនទី ៥ - ន្វប្វវ៉ាត្ត់ ........................................ ២៤

មេរៀនទី ៦ - អ៊ីម៉ាម៉ាត្ត់ ........................................ ៣១

មេរៀនទី ៧ - គ្វីយ៉ាម៉ាត្ត់ ........................................ ៣៨

មេរៀនទី ៨ - ហ្វ៊្យូរអ្រុដ្វឌ្វីន - អារម្ភកថា ........................ ៤៥

មេរៀនទី ៩ - សាឡើងវិញ - សូត្រក្នុងស្វ៍ឡាត្ត់ ............. ៤៩

មេរៀនទី ១០ - នៀត ........................................ ៦០

មេរៀនទី ១១ - គ្វីបឡាស្ត់ ........................................ ៦៦

មេរៀនទី ១២ - ពេលវេលាស្វ៍ឡាត្ត់ ............................ ៧២

មេរៀនទី ១៣ - តាក្រុ់គ្វីបាត់ - តាស់ប៊ិះហ្រ៍ - ស៊្រីយ៉ារ៉ត្ត់ .... ៧៨

មេរៀនទី ១៤ - អ្វីដែលធ្វើឲ្យខូចវ្ឌុអ៊ុំ ......................... ៨៧

មេរៀនទី ១៥ - ទង្វើដែលបណ្ដាលឲ្យខូចស្វ៍ឡាត្ត់ ......... ៩០

មេរៀនទី ១៦ - ត្ត៍ហ្វាព៉ោះត្ត៍ និង ណាយ៉្ជាសាស្ត់ ........... ៩៣

មេរៀនទី ១៧ - ស្ទៅម៍ ........................................ ៩៧

មេរៀនទី ១៨ - ហ្វ៊ីយ៉្ជាប់ (សម្រាប់នារី) ...................... ១០០

របស់រថយន្ត ដើម្បីនឹងឲ្យគេយល់ជ្រួតជ្រាបឲ្យបានល្អ ។

ដូចគ្នាដែរ ព្រះសាស្តាទាំងអស់(عليهم السلام)បានបង្ហាត់បង្រៀនថា មានព្រះតែមួយគត់ ហើយខ្លួនព្រះអង្គជាសាស្តារបស់ព្រះ ។ ក៏ប៉ុន្តែអល់ឡោះហ្វ៍ដាក់ច្បាប់សាសនាមក ដោយថ្លឹងតាមសមត្ថភាពរបស់ប្រជារាស្ត្រ ថាតើគេមានលក្ខណៈគ្រប់គ្រាន់ហើយឬនៅដើម្បីយល់ច្បាប់ទាំងនោះ ។ នៅទីបញ្ចប់ សាសនាអ៊ីស្លាមពេញលេញ ត្រូវដាក់មកលើពិភពលោកទាំងមូលតាមរយៈព្រះសាស្តាមូហាំម៉ាដ់ﷺ ។



## មេរៀនទី ១

អ៊ីស្លាមមានសេចក្តីថា ស្តាប់ឱវាទអល់ឡោះហ្វ៍ទាំងស្រុង ។ អល់ឡោះហ្វ៍បានបង្កើតយើងមក ដូច្នេះព្រះអង្គទ្រង់ញាណអ្វីដែលល្អនិងអាក្រក់សម្រាប់យើង ។ អនុវត្តតាមសាសនាអ៊ីស្លាមយ៉ាងតឹងរ៉ឹង (ដោយចាត់ទុកសាសនាអ៊ីស្លាមជារបៀបរស់នៅ មិនចាត់ទុកត្រឹមតែជាសាសនាទេ) យើងនឹងបានស្ងប់ក្នុងចិត្ត ។ ពាក្យថាអ៊ីស្លាមចេញមកពីពាក្យថា សាឡាម មានន័យថាសេចក្តីសុខ សេចក្តីស្ងប់សន្តិសុខ... ។

អ៊ីស្លាមមិនដូចសាសនាឯទៀតទេ ដែលហៅតាមឈ្មោះរបស់ស្ថាបនជន (អ្នកបង្កើត អ្នកសាង) ឬតាមឈ្មោះរបស់កន្លែងណាមួយ ដែលសាសនានោះបានកើតឡើង ។ ឧទាហរណ៍៖

១) ឈ្មោះរបស់សាសនាយ៉ាហ្វ៉ូឌី ហៅតាមឈ្មោះកុលសម្ព័ន្ធយូដ្ឋា ដែលរស់នៅឯតំបន់មួយដែលមានឈ្មោះដូចគ្នា ។
២) សាសនាគ្រិស្ត ហៅតាមឈ្មោះរបស់គ្រិស្ត (ណាប៊ីអ៊ីសា(عليه السلام)) ។

សាសនាអ៊ីស្លាម មិនហៅតាមឈ្មោះរបស់ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ទេព្រោះយើងមិនជឿថា ព្រះអង្គជាអ្នកបង្កើតសាសនាអ៊ីស្លាមទេ ។ សាសនាអ៊ីស្លាមជាសាសនារបស់អល់ឡោះហ្វ៍ ។

អល់ឡោះហ្វ៍មានព្រះបន្ទូលក្នុងគួរអាន ស៊ូរ៉ោះត្ធ៍ អាលីអ៊ីមរ៉ន អាយ៉ាស្ធ៍ ១៩ ថាៈ

*ពិតណាស់ សាសនារបស់អល់ឡោះហ្វ៍គឺសាសនាអ៊ីស្លាម ។ (៣:១៩)*

អល់ឡោះហ្វ៍ ជាពាក្យដែលបណ្តាមុស្លីមប្រើសម្រាប់ហៅថាព្រះ ។ ប្រសើរបំផុតឲ្យប្រើពាក្យ អល់ឡោះហ្វ៍ ជាជាងពាក្យថា ព្រះ ព្រោះថាៈ
ពាក្យថា ព្រះ អាចក្លាយទៅពហុវចនៈរបស់ពាក្យនេះ ពោលគឺ ព្រះច្រើន ។
ពាក្យថា ព្រះ អាចក្លាយទៅឥត្ថីវចនៈ (ភេទស្រី) របស់ពាក្យនេះ ពោលគឺ ទេពធីតា (គឺព្រះស្រី) ។

ពាក្យថា អល់ឡោះហ្វ៍ មិនមានពហុវចនៈនិងមិនមានឥត្ថី



វចនៈទេ ដូច្នេះពាក្យថា អល់ឡោះហ្វ៍ មានន័យថាព្រះជាម្ចាស់ប្រសើរជាងអស់ពាក្យឯទៀត ។ ពោលគឺ មានព្រះតែមួយគត់ ព្រះអង្គមិនមែនប្រុសហើយក៏មិនមែនស្រីទេដែរ ។

អ៊ីស្លាមជាសាសនាដំបូងបង្អស់ និងចុងក្រោយបង្អស់ដែលព្រះសាស្តាទាំងឡាយ عليهم السلام បានបង្ហាត់បង្រៀនឲ្យដឹង គឺព្រះសាស្តាដែលមានចំនួន ១២៤០០០ អង្គ តាំងពីអាដាំ عليه السلام រហូតមកដល់មូហាំម៉ាដ្ឋ ﷺ ។
ការអប់រំមូលដ្ឋានរបស់ព្រះសាស្តាទាំងអស់ عليهم السلام ជាការអប់រំមូលដ្ឋានដូចៗគ្នា ទោះបី ជួនកាលច្បាប់សាសនាខុសគ្នាក៏ដោយ អាស្រ័យលើសម័យរបស់ព្រះសាស្តានិងអាស្រ័យលើបក្កភាពនៃប្រជារាស្ត្ររបស់សម័យនោះ ដែលមានលក្ខណៈគ្រប់គ្រាន់ហើយឬនៅ ដើម្បីទទួលការអប់រំរបស់ព្រះសាស្តា ។

ឧទាហរណ៍ បើសិនជាអ្នកចង់អធិប្បាយអំពីរថយន្តឲ្យកុមារយល់ អ្នកប្រាប់គេជាមុនថាវាមានកង់ ហើយវាអាចដឹកគេពីកន្លែងមួយទៅកាន់កន្លែងមួយទៀត ។ ពេលគេធំបន្តិច អ្នកពន្យល់ប្រាប់គេថា រថយន្តមានម៉ាស៊ីនដែលត្រូវការសាំងដើម្បីដំណើរការបាន ។ ពេលគេធំជាងនោះបន្តិច អ្នកអាចពន្យល់ប្រាប់គេជាពិស្តារ អំពីដំណើរការរបស់ផ្នែកនីមួយៗ

អ៊ីស្លាម ។

មុស្លិមរាល់គ្នាចាំបាច់ត្រូវយល់ អ៊ូស្វូល ឲ្យបានល្អបំផុតតាមសមត្ថភាពរបស់ខ្លួន ។ ក្នុង អ៊ូស្វូល ពុំមានតាក់្លីដ្ (تَقْلِيد ការធ្វើត្រាប់តាម) ទេ តែក្នុង ហ្វ៊ូរូអ៊ុ ត្រូវមានតាក់្លីដ្ជាចាំបាច់ ។

អ៊ូស្វូល អ៊ុដ្ឌីន (ឫសកែវ ឬ គ្រឹះរបស់សាសនា) មាន ៥ ប្រការគឺ៖

១. តៅហ៊ីដ្ (تَوْحيد) : មានតែអល់ឡោះហ្វ៍មួយគត់ ។
២. អ៊ុដ្ឋាឡាត្ហ៍ (عدالة) : អល់ឡោះហ្វ៍យុត្តិធម៌ ។
៣. នូប៊ូវ៉ាត្ហ៍ (نبوة) : អល់ឡោះហ្វ៍បានចាត់បញ្ជូនមកនូវ ១២៤០០០ ព្រះសាស្ដាដើម្បីដឹកនាំយើង ។
៤. អ៊ីម៉ាម៉ាត្ហ៍ (إمامة) : អល់ឡោះហ្វ៍បានចាត់បញ្ជូនមកនូវ ១២ អ៊ីម៉ាំដើម្បីដឹកនាំយើង ។
៥. គ្ហីយ៉ាម៉ាត្ហ៍ (القيامة) : ថ្ងៃជំនុំជម្រះនឹងកើតមានឡើង ។



## កិច្ចការសិស្ស ១

ចូរឆ្លើយសំណួរតទៅនេះគឺ៖

១. តើអ៊ីស្លាមមានន័យថាអ្វី ?

________________________________________

________________________________________

២.ហេតុអ្វីគេមិនហៅសាសនាអ៊ីស្លាម តាមឈ្មោះរបស់ព្រះសាស្ដាមូហ៊្ហាំម៉ាដ្ﷺ ?

________________________________________

________________________________________

៣. ហេតុអ្វីការប្រើពាក្យថា អល់ឡោះហ្វ៍ ប្រសើរជាងការប្រើពាក្យថាព្រះ ?

________________________________________

________________________________________

៤. អ្វីទៅដែលព្រះសាស្ដាទាំងអស់តែងតែថា ?

________________________________________

________________________________________

ចូរទន្ទេញអាយ៉ាស់ ១៩ ស៊ូរ៉ោះត្ហ៍ អាលី អ៊ិមរ៉ន ខាងក្រោម

នេះឲ្យចាំស្ទាត់គឺ៖






**មេរៀនទី ២**

# អ៊ូស្ហ៊ូល អ៊ុដ្ឌីន - អារម្ភកថា

សាសនាអ៊ីស្លាមប្រៀបបាននឹងដើមឈើដែលដុះឫស និង បែកមែក ។

គ្រឹះ (ឬ ឫសកែវ) របស់សាសនាហៅថា អ៊ូស្ហ៊ូល អ៊ុដ្ឌីន (أصول الدين) ។

មែកឬសាខារបស់សាសនាហៅថា ហ្វ៊ូរូអ៊ុដ្ឌីន (فروع الدين) ។ ដូចដើមឈើដែរ ឫសសំខាន់ជាងមែក ក្នុងសាសនាអ៊ីស្លាម អ៊ូស្ហ៊ូល សំខាន់បំផុតសម្រាប់ជំនឿជាង ហ្វ៊ូរូអ៊ុ ទៅទៀត ។ បើគេកាត់មែកឈើ ដើមឈើនៅតែរស់មែកវានឹងដុះឡើងវិញបន្តិចម្តងៗ តែបើគេកាត់ឫសវា ដើមឈើនឹងស្លាប់ ។ ដូចគ្នាដែរ បើគេមិនយល់ ហ្វ៊ូរូអ៊ុ (គឺមែក) យ៉ាងជ្រាលជ្រៅទេ គេនៅតែអាចអនុវត្តតាមហ្វ៊ូរូអ៊ុទាំងនោះបាន សាសនានឹងនៅតែមានជាដរាប គេនឹងយល់ន័យម្តងបន្តិចៗ ។ តែបើគេមិនយល់អ៊ូស្ហ៊ូល (គ្រឹះ ឬ ឫសកែវ) ទេ ជំនឿរបស់គេនឹងស្លាប់ ព្រោះវាជាជំនឿមូលដ្ឋានរបស់សាសនា

ប្រសើរបំផុតគឺប្រើពាក្យថា "អល់ឡោះហ្វ៍" ជាជាងពាក្យថា "ព្រះ" ពីព្រោះ ៖

"ព្រះ" អាចក្លាយជាពហុវចនៈរបស់ពាក្យថា "ព្រះ" នេះពោលគឺ ព្រះច្រើន ។

"ព្រះ" អាចក្លាយជាឥត្ថីវចនៈរបស់ពាក្យថា "ព្រះ" នេះពោលគឺ ទេពធីតា ។

ពាក្យថា "អល់ឡោះហ្វ៍" មិនមានពហុវចនៈនិងមិនមានឥត្ថីវចនៈទេ ហើយនេះជាវិធីប្រសើរបំផុតសម្រាប់ហៅអល់ឡោះហ្វ៍ ។ មានតែព្រះមួយគត់ ព្រះអង្គមិនមែនប្រុស ហើយក៏មិនមែនស្រីទេដែរ ។

ជឿតៅហ៊ីដ្ធមានន័យថា អ្នកមិនត្រឹមតែជឿតែព្រះមួយប៉ុណ្ណោះទេ អ្នកថែមទាំងពឹងផ្អែកលើព្រះអង្គក្នុងរឿងអ្វីៗទាំងអស់ហើយអ្នកធ្វើអ្វីគ្រប់យ៉ាងដើម្បីព្រះអង្គ ។

បើអ្នកពឹងផ្អែកលើអល់ឡោះហ្វ៍ទាំងស្រុងពិតមែន ទោះបីក្នុងរឿងអ្វីក៏ដោយ អ្នកនឹងមិនត្រូវការអ្នកណាឡើយ ហើយអ្នកនឹងមិនខ្លាចអ្នកណាឡើយ ។

បើអ្នកធ្វើអ្វីដើម្បីអល់ឡោះហ្វ៍មែន អ្នកច្បាស់ជានឹងយល់ថា



## កិច្ចការសិស្ស ២

ចូរគូរដើមឈើនៅពេល ដែលមានអ្វីកើតឡើងចំពោះវាប្រសិនបើ ៖

១) គេកាត់មែកវា ដូចដែលបង្ហាញនៅលើរូបខាងក្រោមនេះ ។



២) គេកាត់ឫសវា ដូចដែលបង្ហាញនៅលើរូបខាងក្រោមនេះ ។





**មេរៀនទី ៣**

# តៅហ៊្ហីដ្

តៅហ៊្ហីដ្មានន័យថា មានតែអល់ឡោះហ្ម៏ួយគត់ ។

អល់ឡោះហ៏្ពន្យល់តៅហ៊្ហីដ្នៅក្នុងព្រះគម្ពីរគួ្ហរអាន ក្នុង ស៊ូរ៉ោះត៏្ អ៊ីខ្លាស្ញ់ គឺ ៖

| | |
|---|---|
| ដោយព្រះនាមអល់ឡោះហ្ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។ | بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ |
| ចូរអ្នកថ្លែងថា៖ "ព្រះអង្គគឺ អល់ឡោះហ្ ព្រះមួយគត់ | قُلۡ هُوَ ٱللَّهُ أَحَدٌ |
| អល់ឡោះហ្មិនត្រូវការអ្វីឡើយ តែសព្វសារពើត្រូវការព្រះអង្គ | ٱللَّهُ ٱلصَّمَدُ |
| ព្រះអង្គមិនឲ្យកំណើតទេ ព្រះអង្គមិនត្រូវប្រសូតមកទេ | لَمۡ يَلِدۡ وَلَمۡ يُولَدۡ |
| ពុំមានអ្វីដូចព្រះអង្គឡើយ ។" | وَلَمۡ يَكُن لَّهُۥ كُفُوًا أَحَدُۢ |

**មេរៀនទី ៤**

# អាដាឡាត់

អាដាឡាត់ មានន័យថាអល់ឡោះហ្វ៍យុត្តិធម៌ ។

យុត្តិធម៌របស់អល់ឡោះហ្វ៍មិនមានន័យថា អល់ឡោះហ្វ៍ស្មើភាពសម្រាប់មនុស្សទាំងអស់ទេ ។
ស្មើភាពនិងយុត្តិធម៌មិនដូចគ្នាទេ ។
ឧទាហរណ៍ ពេលគ្រូដាក់ពិន្ទុកិច្ចការសិស្សដោយយុត្តិធម៌ សិស្សម្នាក់ៗនឹងទទួលបានពិន្ទុ សមតាមទង្វើរបស់ខ្លួន យោលទៅតាមការប្រឹងប្រែង ។ តែបើគ្រូដាក់ពិន្ទុស្មើគ្នា សិស្សគ្រប់រូបនឹងបានទទួលពិន្ទុស្មើគ្នា ដោយមិនគិតទៅលើការខំប្រឹងប្រែង ។
អ្វីដែលអល់ឡោះហ្វ៍ធ្វើសុទ្ធតែយុត្តិធម៌ ព្រះអង្គមិនតឹងរ៉ឹង ហើយក៏មិនធ្វើអ្វីដែលលំអៀងពីប្រាជ្ញាញាណទេ ។ យើងអាចមិនយល់ថា ហេតុអ្វីអល់ឡោះហ្វ៍ធ្វើអ្វីមួយដែលគួរឲ្យតក់ស្លុត តែមិនមានន័យថាព្រះអង្គអយុត្តិធម៌នោះទេ ។
បើសិនជាអ្នកណាមួយអយុត្តិធម៌ ក៏ព្រោះតែ ៖



អ្វីគឺអ៊ីស្លាម (ជារបៀបរស់នៅ មិនមែនត្រឹមតែជាសាសនាធម្មតាប៉ុណ្ណោះទេ) ។ អ្នកនឹងហូប នឹងផឹក នឹងដេក នឹងសិក្សា នឹងស្តាប់បង្គាប់ ឬនឹងស្រឡាញ់អ្នកដទៃដើម្បីអល់ឡោះហ្វ៍មួយគត់ ។

ថ្ងៃមួយ ប៊ីប៊ី សែណាប់ سلام الله عليها បានសួរអ៊ីមុាំអាលី صلوات الله عليه والسلام ព្រះបិតាព្រះនាង ថាតើព្រះអង្គ صلوات الله عليه والسلام អាចស្រឡាញ់របស់ពីរបានដូចម្តេចទៅ អល់ឡោះហ្វ៍និងខ្លួនព្រះនាងផ្ទាល់ដែលជាបុត្រីរបស់ព្រះអង្គ صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام បានឆ្លើយសំណួរនេះថាព្រះអង្គ صلوات الله عليه والسلام មានតែសេចក្តីស្រឡាញ់មួយប៉ុណ្ណោះ គឺសេចក្តីស្រឡាញ់អល់ឡោះហ្វ៍ ។ សេចក្តីស្រឡាញ់របស់ព្រះអង្គ صلوات الله عليه والسلام ចំពោះបុត្រីព្រះអង្គ صلوات الله عليه والسلام នោះ គឺដោយសារតែអល់ឡោះហ្វ៍បានផ្តាំ ឲ្យព្រះអង្គ صلوات الله عليه والسلام ស្រឡាញ់បុត្រីរបស់ព្រះអង្គ صلوات الله عليه والسلام ។

អល់ឡោះហ្វ៍មានព្រះបន្ទូលថាព្រះអង្គមិនចង់បានទេ បើអ្នកធ្វើអ្វីមួយដើម្បីអ្នកដទៃនោះ ។ បើអ្នកចង់ដឹងថាអ្នកធ្វើអ្វីមួយដើម្បីអល់ឡោះហ្វ៍មែន ចូរអ្នកសង្កេតមើលថាតើអ្នកធ្វើស្វ៍ឡាត់នៅផ្ទះតែម្នាក់ឯង ដូចពេលដែលអ្នកធ្វើស្វ៍ឡាត់នៅឯម៉ាស់យ៉ិដដែរឬទេ ពេលដែលអ្នកផងមើលមកអ្នក ។

## កិច្ចការសិស្ស ៣

ចូរសរសេរន័យរបស់ស្វូរ៉ោះត្ត៍ អាល់-អ៊ីខ្លាស្វ៍ គ្រប់បន្ទាត់នៅខាងក្រោមនេះ និងចូរទន្ទេញឲ្យចាំស្ទាត់ ។




តើអល់ឡោះហ្វ៍បង្គាត់បង្រៀនយើង ឲ្យចេះដឹងអ្វីក្នុង



ស្វូរ៉ោះត្ត៍នេះ ?

## មេរៀនទី ៥

# នូប៊ូវ៉ាត្ត់

នូប៊ូវាត្ត់ (نبوة) គឺជំនឿលើសាស្តា ។

អល់ឡោះហ្វ៍បានចាត់បញ្ជូនមកនូវ ១២៤000 ព្រះសាស្តា عليهم السلام ដើម្បីដឹកនាំយើង ។ ក្នុងចំណោមសាស្តាទាំង ១២៤000 រូបនេះ ព្រះសាស្តាអាដាំ عليه السلام ជាព្រះសាស្តាដំបូងបង្អស់ ហើយក៏ជាមនុស្សដំបូងបង្អស់ដែរ ។ ព្រះសាស្តាចុងក្រោយបង្អស់ ក្នុងចំណោមព្រះសាស្តាទាំងអស់នេះគឺព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ។

ហេតុអ្វីយើងត្រូវការព្រះសាស្តា ?

បណ្តាព្រះសាស្តាមានបេសកកម្មបង្ហាញយើង នូវមាគ៌ាត្រឹមត្រូវ ព្រះអង្គជាមគ្គុទេសក៍យើង ប្រៀបបាននឹងគ្រូបាធ្យាយ ។ ព្រះអង្គជាមនុស្សដូចយើងដែរ ដូច្នេះយើងអាចយកតម្រាប់តាមព្រះអង្គបាន ព្រះអង្គជាគំរូសម្រាប់យើង ។



១) អ្នកនោះអាចមិនដឹងខ្លួនទេថាខ្លួនឯងអយុត្តិធម៌ ។
២) អ្នកនោះចង់បានអ្វីមួយ ដែលខ្លួនមិនអាចយកមកបានដោយមិនប្រព្រឹត្តិដោយអយុត្តិធម៌ ។
៣) អ្នកនោះអាចត្រូវគេបង្ខំឲ្យប្រព្រឹត្តិដោយអយុត្តិធម៌ ។

ករណីទាំងបីខាងលើនេះ មិនស័ក្តិសមនឹងអល់ឡោះហ្វ៍ទេ ពីព្រោះ ៖
១) ព្រះអង្គប្រកបដោយញាណបារមីដ៏ខ្ពង់ខ្ពស់បំផុត ។
២) ព្រះអង្គមិនត្រូវការអ្វីឡើយ ។
៣) ព្រះអង្គមានព្រះមហិទ្ធិឫទ្ធិលើសលុប ។

បុរសម្នាក់ទៅធ្វើស្ឡ៏ឡាត្ត់ថ្ងៃសុក្រ ។ តាមផ្លូវ គាត់បានឆ្លៀតចូលទៅសួរកូនស្រីគាត់ទាំងពីរនាក់នៅឯផ្ទះថា តើកូនទាំងពីរចង់ឲ្យគាត់ជួយបួងសួងអល់ឡោះហ្វ៍ឲ្យឬទេ ក្រោយពីស្ឡ៏ឡាត្ត់រួច ។

កូនម្នាក់បានសូមឲ្យគាត់បួងសួង សូមឲ្យមានភ្លៀងធ្លាក់ ព្រោះស្វាមីគាត់ជាកសិករ គាត់ចង់ឲ្យដំណាំរបស់គាត់ឆាប់ដុះ ។

កូនស្រីម្នាក់ទៀតសូមឲ្យគាត់បួងសួង សូមឲ្យបើកថ្ងៃ ដើម្បី

នឹងឲ្យផើងដែលស្វាមីគាត់ធ្វើពីដីនោះឆាប់ស្ងួត ។

បុរសជាឪពុកបានទៅកាន់ម៉ាស់ឃ្មិដូ អារម្មណ៍ច្របូកច្របល់ មិនដឹងនឹងបួងសួងសូមអ្វីទេ ព្រោះកូនស្រីគាត់ម្នាក់ចង់បានថ្ងៃ ឯម្នាក់ទៀតចង់បានភ្លៀង ។

គាត់បានសម្រេចចិត្តថានឹងបួងសួងអល់ឡោះហ្វ សូមឲ្យព្រះអង្គធ្វើអ្វីតាមតែព្រះអង្គទ្រង់យល់ថាយុត្តិធម៌ចុះ ព្រោះនេះជាការដោះស្រាយត្រឹមត្រូវ ។



## កិច្ចការសិស្ស ៤

តើអល់ឡោះហ្វយុត្តិធម៌ ឬ ស្មើភាព តើខុសគ្នាត្រង់ណា ?

________________________________________
________________________________________
________________________________________
________________________________________
__________________________

នឹងប្រាប់វាថាវាមានកង់ ដែលដឹកអ្នកពីកន្លែងមួយទៅកន្លែងមួយទៀត ។ ពេលកុមារធំបន្តិច មានសមត្ថភាពអាចយល់បានច្រើន អ្នកនឹងប្រាប់វាថារថយន្តអាចផ្លាស់កន្លែងបានអាស្រ័យម៉ាស៊ីនដែលប្រើសាំង ។ ពេលកុមារកាន់តែធំឡើងទៀត អ្នកនឹងប្រាប់វាឲ្យដឹងថាម៉ាស៊ីនមានដំណើរការម្តេចខ្លះ ។ល ។

តាមទម្លាប់ ព្រះសាស្តាមាននូវប្រជុំច្បាប់ (ស្វហ្វរីអ៊ុស្វ) ទុកក្នុងសៀវភៅមួយ ។ គេហៅសៀវភៅទាំងនោះថា ព្រះគម្ពីរ ។

ព្រះសាស្តានុះហ៍(عليه السلام) និងព្រះសាស្តាអ៊ីបរ៉ហ៊ីម(عليه السلام)មានព្រះគម្ពីរមួយម្នាក់ តែយើងមិនដឹងក្រៅពីនេះទេអំពីព្រះគម្ពីរទាំងពីរនេះ ។ ព្រះគម្ពីរឯទៀតដែលយើងស្គាល់ គឺ ៖

-ព្រះគម្ពីរ តៅរ៉ត (توراة) ត្រូវដាក់ចុះមកឲ្យព្រះសាស្តាមូសា(عليه السلام) ។

-ព្រះគម្ពីរ ស្ហាប៊ូរ (زبور) ត្រូវដាក់ចុះមកឲ្យព្រះសាស្តាដាវុដ(عليه السلام) ។

-ព្រះគម្ពីរ អ៊ិនយ៉ីល (إنجيل) ត្រូវដាក់ចុះមកឲ្យព្រះសាស្តាអ៊ីសា(عليه السلام) ។

-ព្រះគម្ពីរ គួរអាន (قرءان) ត្រូវដាក់ចុះមកឲ្យព្រះសាស្តា



បណ្តាព្រះសាស្តាប្រៀបបាននឹងស្ពានរវាងយើង និងអល់ឡោះហ្ស៍(عز وجل) ។

អល់ឡោះហ្ស៍(عز وجل)មានព្រះបន្ទូលមកកាន់ព្រះសាស្តា ដោយមធ្យោបាយមួយ ក្នុងចំណោមមធ្យោបាយបីគឺ ៖

១) ដោយផ្ទាល់ ឧទាហរណ៍ ព្រះសាស្តាមូសា(عليه السلام) ។

២) តាមរយៈសុបិន ឧទាហរណ៍ ព្រះសាស្តាអ៊ីបរ៉ហ៊ីម(عليه السلام) ។

៣) តាមរយៈទេវតា យ៉ីបរ៉អ៊ីល (جبرائيل) ឧទាហរណ៍ ព្រះសាស្តាមូហាំម៉ាដ់ﷺ ។

បន្ទាប់មក ព្រះសាស្តានាំព្រះបន្ទូលអល់ឡោះហ្ស៍(عز وجل)មកប្រាប់យើង ។

ព្រះសាស្តាមួយចំនួនត្រូវចាត់បញ្ជូនទៅ ឯបណ្តាកុលសម្ព័ន្ធ ទៅឯបណ្តាសហាគមន៍និងទៅឯបណ្តាគ្រួសារ (ឬត្រកូល) តាមព្រះបញ្ជាអល់ឡោះហ្ស៍(عز وجل) ។ តែព្រះសាស្តាﷺយើងត្រូវចាត់បញ្ជូនមកកាន់មនុស្សជាតិទាំងអស់ ។

ឋានន្តរស័ក្តិមួយរបស់ព្រះសាស្តាﷺយើង ក្នុងចំណោម

ឋានន្តរសក្តិឯទៀតគឺ រ៉ោះហ្វ៍ម៉ាទុល លិល-អ៊ាឡាមីន មានន័យថា "ពរជ័យសិរីសួស្តីលើភពផែនដែនចក្រវាល" ។ អាស្រ័យហេតុនេះឯង បានជាអល់ឡោះហ្វ៍ ﷻ មិនធ្វើទណ្ឌកម្មភ្លាមៗអ្នកណា ដែលប្រព្រឹត្តល្មើសឥតឈប់ឈរ ដូចកាលពីមុននោះទេ ។

ឧទាហរណ៍ មនុស្សនាសម័យព្រះសាស្តានុះហ៊្វ عليه السلام ត្រូវពន្លង់ទឹក ឯមនុស្សនាសម័យព្រះសាស្តាហ៊្វូដ عليه السلام ត្រូវកបំផ្លាញចោល ។

ព្រះសាស្តាទាំងឡាយត្រូវមានគុណសម្បត្តិដូចតទៅនេះគឺ៖
-ត្រូវអល់ឡោះហ្វ៍ ﷻ ជ្រើសរើស ។
-ជាម៉ាក់ស៊្ហុម (គឺបរិសុទ្ធ) ពោលគឺ មិនមានបាបសោះ ទោះបីបាបដែលបានធ្វើដោយភ្លាំងភ្លាត់ក៏ដោយ ។
-អាចធ្វើឲ្យមានអព្ភូតហេតុបាន ដោយអល់ឡោះហ្វ៍ ﷻ អនុញ្ញាត ។
-ជាបុគ្គលដែលសុក្រឹតបំផុតក្នុងសម័យរបស់ខ្លួន (ដោយអាក់ឡាក់ (أخلاق) ពោលគឺ ដោយមានសីលធម៌និងមានការចេះដឹង) ។

ពាក្យអារ៉ាប់សម្រាប់ហៅព្រះសាស្តាគឺ ណាប៊ី ដែលមាន



ពហុវចនៈថា អាន់ប៊ីយ៉ាអ៊ (أنبياء) ។ ក្នុងចំណោមអាន់ប៊ីយ៉ាអ៊ មួយចំនួនបាននាំមកនូវបញ្ញត្តិថ្មី (ច្បាប់ស្ហារីអ៊ាស់ (شريعة)) ឲ្យប្រជារាស្ត្ររបស់ខ្លួនប្រតិបត្តិតាម គេហៅអាន់ប៊ីយ៉ាអ៊ទាំងនេះថា រ៉ស៊ូល (رسول ឬ ព្រះសាសនទូត) ។ ដូច្នេះឋានន្តរស័ក្តិរ៉ស៊ូលខ្ពស់ជាងឋានន្តរស័ក្តិណាប៊ី ។

មានព្រះសាស្តាប្រាំអង្គ ដែលមានឋានន្តរស័ក្តិខ្ពស់លើសនោះទៀត គេហៅព្រះសាស្តាទាំងនេះថា អ៊ូលុល-អ៊ាស់ម៍ (أولوالعزم សាស្តាពិសេស) មាន ៖

- ព្រះសាស្តា នុះហ៊្វ عليه السلام ។
- ព្រះសាស្តា អ៊ិបរ៉ហ៊ីម عليه السلام ។
- ព្រះសាស្តា មូសា عليه السلام ។
- ព្រះសាស្តា អ៊ីសា عليه السلام ។
- ព្រះសាស្តា មូហាំម៉ាដ់ ﷺ ។

ព្រះសាស្តាបានផ្សាយព្រះរាជសាររបស់អល់ឡោះហ្វ៍ ﷻ តាមសមត្ថភាព ដែលអាចយល់បានរបស់មនុស្សដែលចម្រើនឡើង ដូច្នេះមនុស្សអាចយល់ជាក់ព្រះរាជសាររបស់អល់ឡោះហ្វ៍ខ្លាំងឡើងៗ ។

ឧទាហរណ៍ ដើម្បីពន្យល់កុមារឲ្យយល់ថាអ្វីគឺរថយន្ត អ្នក

(ទាំងវិស័យសីលធម៌ អាក់ឡាក់ ទាំងវិស័យចំណេះចេះដឹង) ។

អាអុីម៉ាស់មានចំនួន ១២ រូប គឺៈ

១) អីមុាំ អុាលី صلوات الله عليه والسلام (علي) ។
២) អីមុាំ ហាសាន់ صلوات الله عليه والسلام (حسن□) ។
៣) អីមុាំ ហុសែន៍ صلوات الله عليه والسلام (حسين□) ។
៤) អីមុាំ អុាលី ស៊ៃនុល-អុាប៊ីឌីន صلوات الله عليه والسلام (علي زين□عابدين) ។
៥) អីមុាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام (محمد□باقر) ។
៦) អីមុាំ យ៉ាក់ហ្វារ អាស់-ស៉ាឌិក صلوات الله عليه والسلام (جعفر□صادق) ។
៧) អីមុាំ មូសា អាល់-កាស៊ីម صلوات الله عليه والسلام (مو□ى□كاظم) ។
៨) អីមុាំ អុាលី អារ-រីដ៉ា صلوات الله عليه والسلام (علي□رضا) ។
៩) អីមុាំ មូហាំម៉ាដ់ អាត់-តាគី صلوات الله عليه والسلام (محمد□تقي) ។
១០) អីមុាំ អុាលី អាន់-ណាគី صلوات الله عليه والسلام (على النقي) ។
១១) អីមុាំ ហាសាន់ អាល់-អុាស់ការី صلوات الله عليه والسلام (□سن□عسكري) ។
១២) អីមុាំ មូហាំម៉ាដ់ អាល់-ម៉ាស់ឌី صلوات الله عليه والسلام (محمد□مهدي) ។

អុីមុាំទី ១២ គឺអុីមុាំ មូហាំម៉ាដ់ អាល់-ម៉ាស់ឌី صلوات الله عليه والسلام ជាអុីមុាំប្រចាំសម័យកាលយើង ព្រះអង្គមានព្រះជន្មនៅឡើយ ។ ដូច្នេះហើយបានជាពេលណាយើងឮព្រះនាមព្រះអង្គ យើង



មូហាំម៉ាដ់ صلى الله عليه وآله وسلم ។

អុីស្លាមជាសាសនាដំបូងបង្អស់ និងចុងក្រោយបង្អស់ដែលព្រះសាស្តាទាំងអស់បាននាំមកបង្ហាត់បង្រៀន ធ្វើឲ្យសុក្រឹត និងបង្គ្រប់ពេញលេញ ដោយព្រះសាស្តាមូហាំម៉ាដ់ មុសតាហ្វា صلى الله عليه وآله وسلم ។

## កិច្ចការសិស្ស ៥

ចូរប្រាប់ព្រះនាមរបស់ព្រះសាស្តាអ៊ូលុល-អា្ហស្ញ៉ម៍ ?

ចូរឆ្លើយសំណួរតទៅនេះគឺ ៖

១) ចូរប្រាប់គុណសម្បត្តិទាំង ៤ ដែលព្រះសាស្តាត្រូវមាន ?

______________________________________________

______________________________________________

_____________________

២) តើណាប៊ី និង រ៉ស៊ូល ខុសគ្នាត្រង់ណា ?

______________________________________________

______________________________________________

_____________________



## មេរៀនទី ៦

# អ៊ីម៉ាម៉ាត្ហ៍

អ៊ីម៉ាម៉ាត្ហ៍ (إمامة) គឺជំនឿលើការចាំបាច់ត្រូវមានមគ្គុទេសក៍ដែលជាអ្នកដឹកនាំក្រោយពីព្រះសាស្តាﷺ ។ ដូច្នេះ មាន ១២ មគ្គុទេសក៍ (អាអ៊ីម៉ាស្ហ៍ أئمة) ។

អាអ៊ីម៉ាស្ហ៍ ជាពហុវចនៈរបស់ពាក្យថា អ៊ីម៉ាំ (إمام) ។ អ៊ីម៉ាំ មានន័យថា មគ្គុទេសក៍ ឬ មេដឹកនាំ ។

ដូចព្រះសាស្តាដែរ អាអ៊ីម៉ាស្ហ៍ចាំបាច់ត្រូវមានគុណសម្បត្តិដូចតទៅនេះគឺ៖

-ត្រូវអល់ឡោះហ្ល៍عزّ وجلّជ្រើសរើស ។

-ជាម៉ាក់ស្ហ៊ុម (បរិសុទ្ធ ជ្រះថ្លា) ពោលគឺ មិនមានបាបសោះទោះបីបាបដែលបានធ្វើដោយភ្លាំងភ្លាត់ក៏ដោយ ។

-អាចធ្វើឲ្យមានអព្ភូតហេតុបាន ដោយអល់ឡោះហ្ល៍عزّ وجلّ អនុញ្ញាត ។

-ជាបុគ្គលដែលសុក្រឹតបំផុត ក្នុងសម័យកាលរបស់ខ្លួន

# កិច្ចការសិស្ស ៦

ចូរបំពេញហ្ហាឌិស្ហ្រព្រះសាស្ដាយើង៖

អ្នកណា__________ __________យើងអ្នកនោះប្រៀបបាន នឹងអ្នកដែល__________ លើនាវារបស់__________ ពួកគេនឹងត្រូវ__________ពីភ្លើង__________ ។



ចូរសរសេរព្រះនាមរបស់អាអ៊ីម៉ាស់ (គឺអ៊ីម៉ាំទាំងអស់) នៅក្នុងក្របខាងក្រោមនេះ ។



គប្បីងើបឈរ ហើយឱនក្បាលដោយដាក់ដៃស្ដាំលើក្បាល ជាកាសម្ដែងសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ចំពោះព្រះអង្គ ។

ព្រះសាស្ដាយើង صلى الله عليه وآله وسلم មានព្រះវចនៈថា មុស្លីមណាស្លាប់ដោយមិនស្គាល់អ៊ីម៉ាំប្រចាំសម័យកាលរបស់ខ្លួន មុស្លីមរូបនោះនឹងស្លាប់ដូចជនអសទ្ធា ។

ហេតុអ្វីយើងត្រូវការអ៊ីម៉ាំជាមគ្គុទេសក៍ ទោះបីព្រះសាស្ដា صلى الله عليه وآله وسلم បានបង្ហាត់បង្រៀនយើង ឲ្យចេះដឹងសាសនាអ៊ីស្លាមសព្វគ្រប់ហើយនោះ ព្រមទាំងបានទុកព្រះមហាគម្ពីរគួរអានឲ្យយើង ?

តួនាទីរបស់អ៊ីម៉ាំគឺដឹកនាំយើង និងជួយយើងពេលណាយើងមិនយល់អ្វីមួយ និងពេលណាយើងភ្លេចភ្លាំង និងដើម្បីជួយធ្វើអន្តរាគមន៍ឲ្យយើងជាមួយអល់ឡោះហ្វ៍ ។

សម័យថ្ងៃមួយ នៅក្នុងម៉ាស់យ៊ិដ្ឋនាប្រទេសអ៊ីរ៉ាក់ មានបុរសម្នាក់ឈ្មោះ អ៊ុំរ៍ ប៊ិន អ៊ូបៃដ៍ បានអះអាងថាលោកមិនជឿថាចាំបាច់ត្រូវមានអ៊ីម៉ាំទេ ។

ហ៊ីស្ហាំ យុវៈនិស្សិតម្នាក់របស់ អ៊ីម៉ាំ យ៉ាក់ហ្វារ អាស្វ-ស្វ៍ឌិក

صلوات الله عليه والسلام បានសួរអុំរ៍ថាបើលោកជឿជាក់យ៉ាងមាំថាមិនចាំបាច់ត្រូវមានអ៊ីម៉ាំទេនោះ តើលោកអាចឆ្លើយសំណួរមួយចំនួនបានទេ ។ អុំរ៍យល់ព្រម ។

ហ៊ីស្សាំបានសួរអុំរ៍ថាតើលោកមានភ្នែកទេ លោកបានតបថាមាន ។

ហ៊ីស្សាំបានសួរថាតើភ្នែកមានប្រយោជន៍អ្វីទៅ អុំរ៍បានតបថាភ្នែកមានប្រយោជន៍សម្រាប់មើល ។

ហ៊ីស្សាំបានសួរអុំរ៍ថាតើលោកមានត្រចៀកទេ លោកបានតបថាមាន ។

ហ៊ីស្សាំបានសួរថាតើត្រចៀកមានប្រយោជន៍អ្វីទៅ អុំរ៍បានតបថាត្រចៀកមានប្រយោជន៍សម្រាប់ស្តាប់ ។
ហ៊ីស្សាំបានសួរបន្តទៀតអំពីច្រមុះ បន្ទាប់ពីនោះមាត់ដូចមុនៗដែរ អុំរ៍បានឆ្លើយ ដោយគិតថាទាំងនេះជាសំណួរភ្លីភ្លើដែលគេសួរលោក ។

បន្ទាប់មក ហ៊ីស្សាំបានសួរថាតើលោកមានខួរក្បាលទេ អុំរ៍បានតបថាមាន ។



ហ៊ីស្សាំបានសួរអំពីអត្ថប្រយោជន៍របស់ខួរក្បាលលោក អុំរ៍បានតបថាខួរក្បាលយល់ នូវអ្វីៗដែលអវយវៈដទៃទទួលដឹង ។

ហ៊ីស្សាំបានសួរអុំរ៍ថាតើមានន័យថា ទោះបីអវយវៈដទៃ (ភ្នែក ត្រចៀក ច្រមុះ មាត់) ជា មិនឈឺក៏ដោយ ក៏មិនអាចធ្វើអ្វីកើតបើគ្មានខួរក្បាលនោះមែនទេ ។ អុំរ៍យល់ស្រប ។

ហ៊ីស្សាំបន្តទៀតថា ដែលអល់ឡោះហ្វ៍បានបង្កើតខួរក្បាលមកនោះក៏ព្រោះតែដើម្បីគ្រប់គ្រងអវយវៈឯទៀត តើអុំរ៍មិនដែលគិតទេឬ ថាអល់ឡោះហ្វ៍ចាត់តាំងមគ្គទេសក៍ (អ៊ីម៉ាំ) មួយរូបដើម្បីបង្ហាញផ្លូវនិងដឹកនាំមនុស្ស ?

អុំរ៍ឆ្លើយមិនរួច ។

ព្រះសាស្តាយើងមានព្រះវចនៈថា៖ "អ្នកណាស្រឡាញ់អាស្ហ៍លុល-បៃត៍យើង អ្នកនោះប្រៀបបាននឹងអ្នកដែលឡើងទៅលើនាវារបស់នុះហ្វ៍ عليه السلام ពួកគេនឹងត្រូវសង្គ្រោះឲ្យផុតពីភ្លើងនរក ។"

យើងមានជីវិតឡើងវិញ ។
ចូរអ្នកចងចាំថាយើងត្រូវបង្កើតមក នៅដើមដំបូងបង្អស់ យើងត្រូវបង្កើតមកពីភាពទទេ គ្មានអ្វីសោះឡើយ ។

## បរលោក

អល់ឡោះហ្វ៍មានព្រះបន្ទូល នៅក្នុងព្រះមហាគម្ពីរគួរអាន ស៊ូរ៉ោះត៊្ហ៍ អាស់-សាច្ច៌ដ្ហាស្ហ៍ (៣២:១៧) ថា ៖

*ពុំមានអ្នកណាមួយអាចដឹងបានឡើយថា គេបម្រុងទុកនូវសេចក្តីរីករាយណាខ្លះទេ សម្រាប់ខ្លួនអ្នកនោះដែលជាការតបស្នងទង្វើដែលពួកគេបានប្រព្រឹត្ត ។*

ត្រង់នេះ គេឲ្យយើងដឹងថាអ្វីដែលយើងនឹកស្មានថាអស្ចារ្យនោះនឹងមិនស្មើឋានសួគ៌បរមសុខទេ ។ ឋានសួគ៌បរមសុខប្រសើរបំផុត ។ យើងមិនអាចប៉ាន់ស្មានបានថានឹងអស្ចារ្យប៉ុណ្ណាទេ ។

ដូចគ្នាដែរ យើងមិនអាចប៉ាន់ស្មានបានថាឋាននរកនឹងអាក្រក់ប៉ុណ្ណាទេ ។ អល់ឡោះហ្វ៍មានព្រះបន្ទូលនៅក្នុងព្រះ





## មេរៀនទី ៧

# គ្ចីយ៉ាម៉ាត្ទ

គ្ចីយ៉ាម៉ាត្ទ ឬ គ្ចីយ៉ាម៉ាស្ទ (القيامة) គឺជំនឿលើថ្ងៃជុំនំជម្រះ ។

គឺថ្ងៃដែលយើងនឹងត្រូវទទួលខុសត្រូវ លើទង្វើទាំងអស់របស់យើង ដែលយើងធ្វើក្នុងលោកនេះ ។ អល់ឡោះហ្វ៍មានព្រះបន្ទូលក្នុងព្រះមហាគម្ពីរគួរអាន ក្នុងស៊ូរ៉ោះត៍ អាល់-មុលក៍ ថា៖

*"ព្រះអង្គបានបង្កើតការស្លាប់និងការរស់រានមានជីវិត ដើម្បីពិសោធឲ្យដឹងថា អ្នកណាខ្លះក្នុងចំណោមពួកអ្នកប្រព្រឹត្តល្អជាងគេ ។" (៦៧:២)*

ហេតុអ្វីគ្ចីយ៉ាម៉ាត្ទ ?

១-អល់ឡោះហ្វ៍មិនបានបង្កើតយើងមក ដោយឥតសារប្រយោជន៍ទេ ដើម្បីជាទីបញ្ចប់របស់យើងពេលណាយើង



ស្លាប់ ។ ពិភពលោកមិនមែនឥតគោលដៅទេ ។ ចូរអ្នកនឹកស្មានថាអ្នកជាវិចិត្រករមួយរូបដែលគូរគំនូរឡើង ដើម្បីតែកម្ទេចវាចោលប៉ុណ្ណោះ បន្ទាប់ពីគូររួច ។

២-តុលាការអល់ឡោះហ្វ៍ (ឬ យុត្តិធម៌អល់ឡោះហ្វ៍) ។ ជនឧក្រិដ្ឋទាំងអស់មិនទទួលខុសត្រូវទង្វើខ្លួនឯងទេ ក្នុងលោកនេះ ។ ជួនកាលពួកគេរួចខ្លួន ។ ដូចគ្នាដែរ ទង្វើល្អមិនបានទទួលការតបស្នងទាំងអស់ទេក្នុងលោកនេះ ឧទាហរណ៍ សាងសង់ម៉ាស់យ៉ិដ្ទ បង្ហាត់បង្រៀនកុមារ ។

តើអល់ឡោះហ្វ៍នឹងបង្កើតយើង សាឡើងវិញដូចម្តេចទៅពេលដែលយើងទៅជាធូលីហើយនោះ ?
អល់ឡោះហ្វ៍មានព្រះបន្ទូល ក្នុងព្រះមហាគម្ពីរគួរអាន (ស៊ូរ៉ោះត៍ កហ្វ ៥០:១៥) ថា៖

*"តើយើងហត់នឿយឬទេ ក្នុងការបង្កើតដំបូង[នូវសត្វលោក]នោះ ? តែពួកគេនៅក្នុងការសង្ស័យ[អំពីរឿងទាក់ទងនឹង]ការបង្កើតថ្មី (ការឲ្យរស់ពីស្លាប់ឡើងវិញ) ។"*

អាយ៉ាស្ទខាងលើនេះឲ្យយើងដឹងថា ដូចអល់ឡោះហ្វ៍បានបង្កើតយើងនាដើមដំបូងនៃជីវិតយើងដែរ ព្រះអង្គនឹងឲ្យ

ទៅជាធូលីហើយនោះ ?

________________________________________

________________________________

តើអល់ឡោះហ្វ៍មានព្រះបន្ទូលថាអ្វីខ្លះអំពីឋានសួគ៌ និងឋាននរក ?

________________________________________

________________________________



មហាគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-អាក់ឡា (៨៧:១៣) ថា ៖

*នៅក្នុងភ្លើងនរកនោះ គេនឹងមិនស្លាប់ទេ ហើយក៏មិនរស់ទេដែរ ។*

គេបានសួរ អ៊ីម៉ាំ ទី ៦ គឺអ៊ីម៉ាំ យ៉ាក់ហ្វារ អាស្ស-ស្វ៉ឌិក្ខ صلوات الله عليه والسلام អំពីអត្ថន័យរបស់អាយ៉ាស់នេះ ។

ព្រះអង្គ صلوات الله عليه والسلام បានឆ្លើយថា អល់ឡោះហ្វ៍បានប្រាប់យើងអំពីឋាននរក និងហេតុដូចម្ដេចយើងមិនអាចរស់និងមិនអាចស្លាប់បាន ។ ព្រះអង្គ صلوات الله عليه والسلام បានអធិប្បាយថាពេលណាស្បែកនិងខ្លួនយើងត្រូវភ្លើងឆេះ គេនឹងឲ្យយើងមានស្បែកនិងខ្លួនថ្មី ហើយស្បែកនិងខ្លួននោះនឹងឆេះ ។

បុរសនោះបានសួរអ៊ីម៉ាំ صلوات الله عليه والسلام ថា តើស្បែកថ្មីនេះនឹងត្រូវដាក់ទោសក្នុងភ្លើងដូចម្ដេចទៅ ដោយសារតែបាបកម្មដែលស្បែកចាស់បានធ្វើ ។ អ៊ីម៉ាំ صلوات الله عليه والسلام បានថាស្បែកថ្មីនេះនឹងត្រូវធ្វើឲ្យកើតឡើងវិញដោយស្បែកចាស់ ។ ព្រះអង្គ صلوات الله عليه والسلام លើកជាឧទាហរណ៍នូវដុំឥដ្ឋដែលបែក ហើយទៅជាផង់ គេធ្វើដុំឥដ្ឋឡើងវិញជាមួយផង់ដុំឥដ្ឋចាស់ ។ ដុំឥដ្ឋនេះជាដុំឥដ្ឋថ្មី ហើយជាដុំឥដ្ឋចាស់តែម្ដង ។

ដូចគ្នាដែរ ពួកនរកនឹងត្រូវដុតក្នុងភ្លើង លុះពួកគេឆេះអស់ គេនឹងបង្កើតពួកគេឡើងវិញ ដើម្បីនឹងត្រូវគេដុតម្តងហើយម្តងទៀតលុះត្រាតែពួកគេជ្រះបាប ។



## កិច្ចការសិស្ស ៧

តើអ៊ីមុាំ យ៉ាក់ហ្វារ អាស្ស-ស្វឌិក្វ صلوات الله عليه والسلام អធិប្បាយម្តេចខ្លះក្នុងការលើកដុំឥដ្ឋជាឧទាហរណ៍ ?



ហេតុអ្វីត្រូវមានគ្វីយ៉ៅម៉ាត្ត ?

______________________________________________

______________________________________________

_______

តើអល់ឡោះហ្វ៍នឹងបង្កើតយើងឡើងវិញដូចម្តេច ពេលយើង

ដូចដើមឈើដែរដែលមានឫសនិងមានមែក ។ ឫសជាគ្រឹះរបស់ដើមឈើដែលបែកមែកសាខា ។ អ៊ីស្លាមស្ថិតនៅលើ អ៊ូស្វូល អ៊ុដ្ឌីន (ឫស ឬ គ្រឹះ) និងលើ ហ្វ៊ូរូអ៊ុដ្ឌីន (សាខា) ។ កាលណាគ្រឹះរឹងមាំ ដោយយល់និងជឿអ៊ូស្វូល អ៊ុដ្ឌីន កាលនោះនឹងមានឡើងនូវទង្វើ ពោលគឺ ហ្វ៊ូរូអ៊ុដ្ឌីន ។



**មេរៀនទី ៨**

# ហ្វ៊ូរូអ៊ុដ្ឌីន - អារម្ភកថា

ហ្វ៊ូរូអ៊ុដ្ឌីន (فروع الدين) គឺសាខារបស់សាសនា ។

ហ្វ៊ូរូអ៊ុដ្ឌីន មាន ១០ ប្រការគឺ ៖

១) ស្វ៉ឡាត្ញ ។
២) ស្វៅម៍ (صوم) - ត្រណមអាហារ ។
៣) ហ្ចាជ្ជ៍ (حج) - ពិធីបូជនីយេសចរណ៍ ។
៤) ស្ហាកាត្ញ (زكاة) - ពន្ធ ។
៥) ឃុមស៍ (خمس) - ពន្ធ ។
៦) យ្ជីហ្វាដ្ឋ (جهاد) - សន្តសង្គ្រាម ។
៧) អាំរ៍ ប៊ិល-ម៉ាក់រូហ្វ (ا□ر بالمعروف) - បង្គាប់ឲ្យធ្វើល្អ ។
៨) ណាហ្ហ៊ី អ៊ុនីល មុនការ (نهى عن المنكر) - ហាមធ្វើអាក្រក់ ។
៩) តាវ៉ាល់ឡា (تولّى) - រក្សាមិត្តភាពរវាងមិត្តអាស្ហ៊ លុល-បៃត៍ ។

១០) តាបារ៉ (تبرأ) - ប្រឆាំងសត្រូវរបស់អាស្វ់ លុល-បៃត៍ ។

ទាំងនេះជាវ៉ាយ៉ិប ត្រូវតែប្រតិបត្តិតាម ។

ពុំមានតាក្វ៉លីដ្វទេ (تَقْلِيد ការធ្វើត្រាប់តាម) ក្នុង អ៊ូស៊្វូល អ៊ុដ្វឌីន (أصول الدين) តែមាន តាក្វ៉លីដ្វក្នុងហ្វ៊ូរូអ៊ុដ្វឌីន ។



## កិច្ចការសិស្ស ៨

ចូរសរសេរន័យរបស់ហ្វ៊ូរូអ៊ុដ្វឌីននីមួយៗ នៅលើដើមឈើខាងក្រោម ។ ចូរទន្ទេញឲ្យចាំ ។



អស់) ។

៦) **សាច់ដ្ញាស់**

سُبْحَانَ رَبِّيَ الْاَعْلٰى وَ بِحَمْدِهِ

សូមថ្វាយសេចក្តីរុងរឿង ចំពោះព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំ ព្រះដ៏ខ្ពង់ខ្ពស់ សូមថ្វាយសេចក្តីសរសើរទាំងអម្បាលម៉ាន ចំពោះព្រះអង្គ ។

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَاٰلِ مُحَمَّدٍ

ឱអល់ឡោះហ្វ៍! សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្តី ដល់មូហាំម៉ាដ់ﷺ និងដល់ក្រុមគ្រួសារعليهم السلامរបស់មូហាំម៉ាដ់ ﷺ ។

៧) **យូលុស**

اَللّٰهُ اَكْبَرُ

អល់ឡោះហ្វ៍ធំធ្ងើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

៨) ពេលងើបឡើងវិញដើម្បីចាប់ផ្តើមរ៉ក់អ៊ុគុ៎បន្ទាប់៖



**មេរៀនទី ៩**

# សាឡើងវិញ - សូត្រក្នុងស្វ៊ឡាត់

១) **នីយ៉ាម**

ខ្ញុំធ្វើស្វ៊ឡាត់________________ ____រ៉ក់អ៊ុគុ៎

قُرْبَةً اِلَى اللهِ

ដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ្វ៍ ។

اَللّٰهُ اَكْبَرُ

អល់ឡោះហ្វ៍ធំធ្ងើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

សូត្រស៊ូរ៉ោះត៍ អាល់-ហ្វាទីហ៊ាស់ និង ស៊ូរ៉ោះត៍គួរអានមួយទៀត

២) **រូគុអ៊ុ៍**

سُبْحَانَ رَبِّيَ الْعَظِيْمِ وَ بِحَمْدِهِ

សូមថ្វាយសេចក្ដីរុងរឿង ចំពោះព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំ ព្រះដ៏ធំធ្ងើង សូមថ្វាយសេចក្ដីសរសើរទាំងអម្បាលម៉ាន ចំពោះព្រះអង្គ ។

اللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَاٰلِ مُحَمَّدٍ

ឱអល់ឡោះហ្វ៍! សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្ដី ដល់មូហាំម៉ាដ់ﷺ និងដល់ក្រុមគ្រួសារعليهم السلامរបស់មូហាំម៉ាដ់ ﷺ ។

៣) **គីយ៉ាម**

سَمِعَ اللّٰهُ لِمَنْ حَمِدَهِ

អល់ឡោះហ្វ៍ទ្រង់សវនាការអ្នកសរសើរព្រះអង្គ

اَللّٰهُ اَكْبَرُ

អល់ឡោះហ្វ៍ធំធ្ងើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

៤) **សាច់ដ្ងាស់**

سُبْحَانَ رَبِّيَ الْاَعْلٰى وَ بِحَمْدِهِ



សូមថ្វាយសេចក្ដីរុងរឿង ចំពោះព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំ ព្រះដ៏ខ្ពង់ខ្ពស់ សូមថ្វាយសេចក្ដីសរសើរទាំងអម្បាលម៉ាន ចំពោះព្រះអង្គ ។

اللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَاٰلِ مُحَمَّدٍ

ឱអល់ឡោះហ្វ៍! សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្ដី ដល់មូហាំម៉ាដ់ﷺ និងដល់ក្រុមគ្រួសារعليهم السلامរបស់មូហាំម៉ាដ់ ﷺ ។

៥) **យូលុស**

اَللّٰهُ اَكْبَرُ

អល់ឡោះហ្វ៍ធំធ្ងើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

اَسْتَغْفِرُ اللّٰهَ رَبِّيْ وَ اَتُوْبُ اِلَيْهِ

ខ្ញុំសូមខមាទោសចំពោះអល់ឡោះហ្វ៍ ព្រះម្ចាស់ខ្ញុំ ហើយខ្ញុំត្រឡប់មករកព្រះអង្គវិញ ដោយសូមស្បារលាលែងធ្វើកំហុសទៀត ។

اَللّٰهُ اَكْبَرُ

អល់ឡោះហ្វ៍ធំធ្ងើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំង

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

ឱអល់ឡោះហ្វ៍! សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្តីដល់មូហាំម៉ាដ់ صلى الله عليه وآله وسلم និងដល់ក្រុមគ្រួសារ عليهم السلام របស់មូហាំម៉ាដ់ صلى الله عليه وآله وسلم ។

១៣) ក្នុងរ៉ក់អាត់ទី ៣ និង ទី ៤ នៅពេលឈរត្រង់យ៉ាម អ្នកត្រូវសូត្រ តាស់ប៊ីហ្វាត់ អារបាអាស់ (تسبيحات اربعه) ៣ ដង គឺ៖

سُبْحَانَ اللهِ وَ الْحَمْدُ لِلّٰهِ وَ لَا اِلٰهَ اِلَّا اللهُ وَ اللهُ اَكْبَرُ

សូមថ្វាយសេចក្តីសរសើរចំពោះអល់ឡោះហ្វ៍ សូមថ្វាយសេចក្តីរុងរឿងចំពោះអល់ឡោះហ្វ៍ មិនមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ អល់ឡោះហ្វ៍ធំធ្មើងបំផុត ។



بِحَوْلِ اللهِ وَ قُوَّتِهِ اَقُوْمُ وَ اَقْعُدُ

ខ្ញុំក្រោកឡើងនិងអង្គុយ អាស្រ័យដោយកម្លាំងនិងឥទ្ធិពលរបស់អល់ឡោះហ្វ៍ ។

៩) ក្នុងរ៉ក់អាត់ទី ២ ពេលឈរត្រង់យ៉ាម (គឺរ៉អាត់ قرآت) សូត្រស៊ូរ៉េះត៍ អាល់-ហ្វាទីហ្វាស់ និង អាល់-អ៊ីខ្លាស់ ។

១០) **គូនូត**

رَبَّنَا اٰتِنَا فِيْ الدُّنْيَا حَسَنَةً وَّ فِيْ الْاٰخِرَةِ حَسَنَةً وَّ قِنَا عَذَابَ النَّارِ

ឱព្រះជាម្ចាស់របស់អស់ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គព្រះរាជទានឲ្យអស់ទូលព្រះបង្គំជាខ្ញុំ នូវសេចក្តីល្អសម្រាប់លោកនេះនិងលោកមុខ ហើយសូមព្រះអង្គឲ្យអស់ទូលព្រះបង្គំជាខ្ញុំបានរួចផុតពីភ្លើងនរកផង ។

១១) **រូគុអ៊ុ, គ្នីយ៉ាម**
**សាច់ដ្ហាស់, យូលុស**
**សាច់ដ្ហាស់, យូលុស**
} ដូចរ៉ក់អាត់ទី ១

១២) ពេលអង្គុយយ្ជូលុស ៖

-តាស្ហាស់ហ៊្វុដ បើស្វ៉ឡាត់ ៣ ឬ ៤ រ៉ក់អ្អាត់ ។

-តាស្ហាស់ហ៊្វុដ និង សាឡាម បើស្វ៉ឡាត់ ២ រ៉ក់អ្អាត់ ។

**តាស្ហាស់ហ៊្វុដ**

اَشْهَدُ اَنْ لَا اِلٰهَ اِلَّا اللّٰهُ وَحْدَهُ لَا شَرِيْكَ لَهُ

ខ្ញុំប្តេជ្ញាថាពុំមានព្រះផ្សេងពីអល់ឡោះហ៍ឡើយ ព្រះអង្គឯកឯង ពុំមានសហការីឡើយ

وَ اَشْهَدُ اَنَّ مُحَمَّدًا عَبْدُهُ وَ رَسُوْلُهُ.

ខ្ញុំសូមប្តេជ្ញាថាមូហាំម៉ាដ់ជាបាវបម្រើរបស់ព្រះអង្គ និងជាសាស្តារបស់ព្រះអង្គ ។

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

ឱអល់ឡោះហ៍! សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្តីដល់មូហាំម៉ាដ់ﷺ និងដល់ក្រុមគ្រួសារعليهم السلامរបស់មូហាំម៉ាដ់ ﷺ ។

**សាឡាម**



اَلسَّلَامُ عَلَيْكَ اَيُّهَا النَّبِيُّ وَ رَحْمَةُ اللّٰهِ وَ بَرَكَاتُهُ

សូមឲ្យសិរីសួស្តី (របស់អល់ឡោះហ៍) កើតមានដល់ព្រះអង្គឱបណ្តាសាស្តាអឺយ ព្រមទាំងព្រះមេត្តាធម៌របស់អល់ឡោះហ៍ និងពរជ័យរបស់ព្រះអង្គ ។

اَلسَّلَامُ عَلَيْنَا وَ عَلٰى عِبَادِ اللّٰهِ الصَّالِحِيْنَ

សូមឲ្យសិរីសួស្តីកើតមានដល់យើង និងដល់បណ្តាបាវបម្រើមានសទ្ធារបស់អល់ឡោះហ៍ ។

اَلسَّلَامُ عَلَيْكُمْ وَ رَحْمَةُ اللّٰهِ وَ بَرَكَاتُهُ

សូមឲ្យសិរីសួស្តីកើតមានដល់ ព្រះអង្គទាំងឡាយ (មូហាំម៉ាដ់និងព្រះរាជកុលដ្ឋានព្រះអង្គ និងបណ្តាសាស្តា និងទេវតា) ព្រមទាំងព្រះមេត្តាធម៌របស់អល់ឡោះហ៍និងពរជ័យរបស់ព្រះអង្គ ។

បន្ទាប់មក សូត្រ ៣ ដង ព្រមទាំងលើកដៃរាល់ដង ថា៖

اَللّٰهُ اَكْبَرُ

អល់ឡោះហ៍ធំថ្កើងបំផុត ។

បន្ទាប់មកទៀត សូត្រ ៣ ដង ថា៖

## មេរៀនទី ១០

# នៀត

នៀត (نِيّة) គឺបំណងរបស់អ្នក អ្វីដែលអ្នកនឹងធ្វើ ។

មុននឹងធ្វើអ្វីក៏ដោយ អ្នកត្រូវនៀតជាទម្លាប់ ទោះបីទង្វើនោះជាទង្វើធម្មតាក៏ដោយ (ឧទាហរណ៍ បរិភោគ ជាដើម) ។

ទង្វើដែលអ្នកនៀតធ្វើនោះ គម្បីធ្វើដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ៍ គឺ៖ "គ្ហូរបាតាន់ អ៊ីលឡុលឡោះហ៍" ។

ធ្វើដូច្នេះអ្នកនឹងទទួលបាននូវស្វាវ៉ាប់ក្នុងគ្រប់ទង្វើ ។

ចូរអ្នកចងចាំថា នៀតរបស់អ្នកចាំបាច់ត្រូវស្មោះត្រង់ ដូច្នេះបើអ្នកធ្វើដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ៍ អ្នកគប្បីធ្វើទង្វើស្វលាត្ហ៍ទាំងអស់ ។

ក្នុងទង្វើមួយចំនួន នៀតជាវ៉ាជិប (អ្នកចាំបាច់ត្រូវតែធ្វើ)



# កាយវិការក្នុងស្វ៉ឡាត្ហ៍



តាក់ប៊ីរ៉ទុល អិះហ្រ៊ារ៉ម គ្ហីយ៉ាម រូគុអ៊ុ គ្ហីយ៉ាម សាច់ដ្វាស់



យ៉ូលុស សាច់ដ្វាស់ យ៉ូលុស គ្ហីយ៉ាម គ្ហុនូត



រូគុអ៊ុ គ្ហីយ៉ាម សាច់ដ្វាស់ យ៉ូលុស សាច់ដ្វាស់



យ្ហូលុស (ចប់)



តាក់ប៊ីរ៉ទុល គ្គីយ៉ាម រុគុអ៍ គ្គីយ៉ាម សាច់ដ្ជាស់
អិះហ្រ៉ម



យ្ហូលុស សាច់ដ្ជាស់ យ្ហូលុស គ្គីយ៉ាម គ្ហុនូត





រុគុអ៍ គ្គីយ៉ាម សាច់ដ្ជាស់ យ្ហូលុស សាច់ដ្ជាស់



យ្ហូលុស(ចប់)

## កិច្ចការសិស្ស ១០

ចូរគូរនៅខាងក្រោមនេះអ្វីដែលបុរសរូបនោះបានធ្វើដើម្បីរែ ឆ្ក ។



ហេតុអ្វីបុរសមិនទទួលបាននូវស្វាវ៉ាប់ ?

______________________________________________

__________________________________

តើនៀតមានន័យថាអ្វី ?

______________________________________________

__________________________________

តើ "គូ្វរបាតាន់ អ៊ិលឡុលឡោះហ្វ៍" មានន័យថាអ្វី ?

______________________________________________

__________________________________



ឧទាហរណ៍ ស្វ៏ឡាត្ទ់ ។

មុននឹងចាប់ផ្តើមធ្វើស្វ៏ឡាត់ អ្នកចាំបាច់ត្រូវតែនៀត ។

ក្នុងពេលនៀត អ្នកចាំបាច់ត្រូវតែ ៖

១) ថាឈ្មោះស្វ៏ឡាត្ទ់ដែលអ្នកចង់ធ្វើ ។

២) ថាតើស្វ៏ឡាត្ទ់នោះជាវ៉ាយ៊ិប ឬ ជាស៊ូណាត្ទ់ ។

៣) ថាតើស្វ៏ឡាត្ទ់នោះជាអាដ្វាអ៊ុ៍ (اداء ក្នុងពេលកំណត់) ឬ ជាក៏្វដ្វ៏ (قضي ក្រៅពេល ពោលគឺ សង) ។

៤) ស្វ៏ឡាត់ត្រូវតែ "គូ្វរបាតាន់ អ៊ីលឡុលឡោះហ្វ៍"

៥) នៀតចាំបាច់ត្រូវតែដដែលដូចដើមលុះចប់ស្វ៏ឡាត្ទ់ ។ បើនៀតរបស់អ្នកមិនមែន នៀតដើម្បីអល់ឡោះហ្វ៍ទេ ព្រះអង្គមិនទទួលស្វ៏ឡាត្ទ់របស់អ្នកទេ ។

សម័យថ្ងៃមួយ បុរសអ្នកសទ្ធាសប់ចិត្តម្នាក់តែងតែភ្ញាក់ពីដំណេកមុនពេលស្វ៏ឡាត្ទ់ អាល់-ហ្វាច៉្វរ៍ដើម្បីធ្វើស្វ៏ឡាត្ទ់តាហ្វាច៉្វយុ៉ដ្វ (تهجد) ។

ថ្ងៃមួយ កំពុងតែធ្វើស្វ៏ឡាត្ត់ក្នុងម៉ាស់ឃ្ជិដ្ឋ គាត់បានឮស្នូរនៅក្រោយខ្នងគាត់ ។ គាត់នឹកក្នុងចិត្តថាមានគេចូលមកក្នុងម៉ាស់ឃ្ជិដ្ឋ គាត់ក៏បានចាប់ផ្តើមបំពេញស្វ៏ឡាត្ត់យឺតៗដោយផ្ចិតផ្ចង់ ដើម្បីសម្លែងអ្នកដែលទើបនឹងចូលមកក្នុងម៉ាស់ឃ្ជិដ្ឋ ។

បុរសរូបនេះបានបំពេញស្វ៏ឡាត្ត់ យ៉ាងយកចិត្តទុកដាក់យ៉ាងយឺតៗ ដោយប្រយ័តប្រយែងក្នុងការសូត្រឲ្យបានច្បាស់គ្រប់ម៉ាត់ ឲ្យត្រឹមត្រូវតាមម៉ាក្ជ់រ៉ច្ជ តម្រូវឲ្យគាត់ប្រើពេលយូរជាងធម្មតាពីរដង ។

លុះចប់ គាត់បានក្រឡេកទៅមើលថាតើអ្នកណាបានចូលមកក្នុងម៉ាស់ឃ្ជិដ្ឋ ។ គាត់បានឃើញឆ្កែកំពុងតែអង្គុយនៅទីនោះ ។

បុរសរូបនេះបានងើបតាំងពីព្រលឹម បានខិតខំចំណាយពេលព្យាយាមក្នុងការបំពេញស្វ៏ឡាត្ត់ នៅទីបំផុតការប្រឹងប្រែងរបស់គាត់គឺដើម្បីឆ្កែ ។

ដើម្បីនឹងដឹងថាតើនៀតរបស់អ្នក "គ្ជូរបាតាន់



អ៊ិលឡុលឡោះហ្វ៍" ឬទេ ចូរអ្នកសម្គាល់មើលខ្លួនអ្នកធ្វើស្វ៏ឡាត្ត់ដូចម្តេចខ្លះពេលអ្នកនៅឯផ្ទះតែម្នាក់ឯង និងពេលអ្នកនៅឯម៉ាស់ឃ្ជិដ្ឋពេល ដែលមនុស្សសម្លឹងមើលមកអ្នក ។ បើសិនជាស្វ៏ឡាត្ត់ទាំងពីររបស់អ្នកខុសគ្នា បានសេចក្តីថានៀតរបស់អ្នកមិន "គ្ជូរបាតាន់ អ៊ិលឡុលឡោះហ្វ៍" ទេ ។

ចូរអ្នកចងចាំថា អ្នកមិនបានស្វាវ៉ាប់ទេបើអ្នកធ្វើដើម្បីអ្នកណាផ្សេងពីអល់ឡោះហ្វ៍ ។

*កាលពីមុន ?" ចូរអ្នកថ្លែង[ឲ្យពួកគេជ្រាប]ថា៖ "ទិសខាងកើតនិងទិសខាងលិចជាកម្មសិទ្ធិរបស់អល់ឡោះហ្វ៍ ។ ព្រះអង្គសព្វព្រះហឫទ័យ ដឹកនាំបុគ្គលណាម្នាក់ឆ្ពោះទៅរកផ្លូវត្រឹមត្រូវស្រេចតែលើព្រះអង្គ ។""*

ព្រឹត្តិការណ៍នេះបានកើតឡើងនៅឯម៉ាស់ឃ៊ិដមួយ ដែលគេស្គាល់ឈ្មោះថា ម៉ាស់ឃ៊ិដ អាល់-គ៊ីបឡាតៃន៍ (المسجد القبلتين) ដែលនៅឯម៉ាឌីណាស់ (المدينة) ។

ព្រះសាស្តាﷺបានបែរទៅរកគ៊ីបឡាស់ថ្មី ដោយឥតរួញរា ។ នេះគឺហេតុការណ៍អស្ចារ្យមួយរបស់ព្រះសាសាﷺ ដែលបានបែរមុខទៅរកព្រះមហាគ្រឹះ កាក់បាស់ ដោយឥតបានប្រើឧបករណ៍វិទ្យាសាស្ត្រណាមួយឡើយ (ឧទាហរណ៍ត្រីវិស័យជាដើម) ។

សព្វថ្ងៃនេះ គេអាចរកគ៊ីបឡាស់ (ទិសស៊ូឡាត់) ឃើញ ៖

១-ដោយសាកសួរប្រជារាស្ត្រ ។

២-ដោយប្រើត្រីវិស័យនិងកូនសៀវភៅ ដែលមាននូវសេចក្តីបញ្ជាក់ ។

៣-នៅក្នុងម៉ាស់ឃ៊ិដ អាស្រ័យលើ មិះហ្រ៉ាប (مِحْراب កន្លែងលុងចង្អុលបង្ហាញទិសស៊ូឡាត់)



តើអ្នកចាំបាច់ត្រូវនៀតនៅពេលណា ?

________________________________________

________________________________

**មេរៀនទី ១១**

# គ្ឹបឡាស្ល៉

គ្ឹបឡាស្ល៉ (قبلة) គឺទិសដែលយើងបែរទៅរកពេលយើងធ្វើនមស្ការបូជាអល់ឡោះហ្វ៍ (ស្វ៊ឡាត្ល៉) ។

គ្ឹបឡាស្ល៉របស់យើងគឺ កាក់បាស្ល៉ "ផ្ទះអល់ឡោះហ្វ៍" (بيت الله) ។

កាក់បាស្ល៉នៅក្នុង ម៉ាស់យ៉ិឌុល ហ្ការ៉ម (المسجد الحرام) នៅឯម៉ាក់កាស្ល៉ (كعبة) ។

កាលដែលអល់ឡោះហ្វ៍បានដាក់បញ្ជា ឲ្យព្រះសាស្តា (صلى الله عليه وآله وسلم) និងបណ្តាមុស្លីមធ្វើនមស្ការ (ស្វ៊ឡាត្ល៉) ប្រចាំថ្ងៃនាគ្រាដំបូង ពួកគេបានបែរមុខទៅរក បៃទុល មូក្កូដ្ដ៉ឌ្ទីស (بيت المقدس យេរូសាលិម) ។ គេបានធ្វើដូច្នេះតរៀងមករហូតដល់ខែទី ១៧ ក្រោយហ្ហ៊ីច្រ៉ោះត្ល៍ (هجرة) ។



ថ្ងៃមួយ ពេលដែលព្រះសាស្តា (صلى الله عليه وآله وسلم) និងបណ្តាមុស្លីមកំពុងតែបំពេញស្វ៊ឡាត្ល៉រួមគ្នា ព្រះបញ្ញត្តិអល់ឡោះហ្វ៍បានដាក់មកថាឲ្យផ្លាស់គ្ឹបឡាស្ល៉ពី បៃទុល មូក្កូដ្ដ៉ឌ្ទីស ទៅរកព្រះមហាគ្រឹះ កាក់បាស្ល៉ វិញ ។

បន្ទាប់ពីព្រះសាស្តា (صلى الله عليه وآله وسلم) បានបំពេញស្វ៊ឡាត្ល៉ពីររ៉ក់អ៊ាត្ល៉ ទេវតាយ៉ិបរ៉អ៊ីល (عليه السلام) បាននាំព្រះរាជសាររបស់អល់ឡោះហ្វ៍ (عز وجل) មកឲ្យព្រះអង្គ (صلى الله عليه وآله وسلم) ។ ព្រះអង្គ (عليه السلام) បានចាប់ដៃព្រះសាស្តា (صلى الله عليه وآله وسلم) ហើយបានបំបែរព្រះអង្គ (صلى الله عليه وآله وسلم) ទៅរកព្រះមហាគ្រឹះ កាក់បាស្ល៉ ឯ ម៉ាស់យ៉ិឌុល ហ្ការ៉ម នានគរម៉ាក់កាស្ល៉ ។

ព្រះសាស្តា (صلى الله عليه وآله وسلم) បានផ្លាស់ទិសភ្លាម កណ្តាលស្វ៊ឡាត្ល៉តែម្តង ។ អ៊ីម៉ាំអ៊ាលី (صلوات الله عليه والسلام) បានផ្លាស់ប្តូរតាមភ្លាមដែរ ។ មុស្លីមឯទៀតស្រឡាំងកាំងដោយសារទង្វើនេះ អ្នកខ្លះបានធ្វើតាមដូចអ៊ីម៉ាំអ៊ាលី (صلوات الله عليه والسلام) ដែរ ។

អល់ឡោះហ្វ៍ (عز وجل) មានព្រះបន្ទូលក្នុងគួរអាន ស៊ូរ៉ោះត្ល៍ អាល់-បាក៏រ៉ោះត្ល៍ (២:១៤២) ថា៖

*"មនុស្សភ្លីភ្លើក្នុងចំណោមបណ្តាមនុស្សនឹងនិយាយថា៖ "អ្វីជាមូលហេតុបណ្តាលឲ្យពួកគេ (ពួកមុស្លិម) បែរចេញពីទិស (គ្ឹបឡាស្ល៉) ដែលពួកគេធ្លាប់បែរទៅរក[ពេលធ្វើនមស្ការ]*

**មេរៀនទី ១២**

# ពេលវេលាស្វ៏ឡាត់

ស្វ៏ឡាត់នីមួយសុទ្ធតែមានពេលវេលាពិសេសរបស់វា ។

អល់ឡោះហ្វ៍មានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះតុ៍ បានី-អ៊ីស្រ៉អ៊ីល ១៧:៧៨) ថា៖

*"ចូរអ្នកធ្វើនមស្ការពីពេលថ្ងៃជ្រេ រហូតដល់ពេលងងឹតនៃពេលយប់ និង[ចូរអ្នក]សូត្រពេលមុនថ្ងៃរះ (ធ្វើនមស្ការបូជាអល់ឡោះហ្វ៍ពេលមុនថ្ងៃរះ សូត្រគួរអាន) ។ ព្រោះការសូត្រ (ធ្វើនមស្ការបូជាអល់ឡោះហ្វ៍ពេលមុនថ្ងៃរះ សូត្រគួរអាន) ពេលមុនថ្ងៃរះនោះមានបណ្ដាសាក្សី (ទេវតា) ។" [១៧:៧៨]*

អាយ៉ាត់ខាងលើនេះបញ្ជាក់ឲ្យយើងដឹងថា ពេលវេលារបស់ស្វ៏ឡាត់គឺមាន ៖



៩-ដោយអាស្រ័យលើផ្នូរមុស្លីម (គេកប់សពដោយដាក់ផ្ដេកលើខាងស្ដាំខ្លួន បែរមុខទៅរកគិ្ហបឡាត់) ។

បើអ្នកមិនស្គាល់ទិសគិ្ហបឡាត់ទាល់តែសោះ ហើយមិនមានមធ្យោបាយរកឃើញទេ អ្នកគប្បីបំពេញស្វ៏ឡាត់ដោយបែរទៅរកទិសទាំងបួន ។

បើអ្នកបានបំពេញស្វ៏ឡាត់ ដោយបែរទៅរកទិសណាមួយក្រោយមកអ្នកបានដឹងថាទិសនោះមិនត្រឹមត្រូវទេ អ្នកគប្បីបំពេញស្វ៏ឡាត់សាឡើងវិញ បើសិនជាអ្នកបានបំពេញស្វ៏ឡាត់នោះ ដោយបែរចេញពីគិ្ហបឡាត់ពិតលើសពី ៩០ អង្សា ។

# កិច្ចការសិស្ស ១១



តើគ្ហីបឡាស្ហ់មានន័យថាអ្វី ?

---

ឯណាគ្ហីបឡាស្ហ់របស់អ្នក ?

---

តើគ្ហីបឡាស្ហ់មុនដំបូងរបស់បណ្តាមុស្លីមគឺអ្វី ?

---

តើការផ្លាស់ប្តូរគ្ហីបឡាស្ហ់ បានប្រព្រឹត្តឡើងនៅឯម៉ាស់ឃ្ជិដ្ឋណា ?

---



តើព្រះសាស្តា صلى الله عليه وآله وسلم កំពុងតែធ្វើអ្វី ពេលដែលព្រះអង្គ صلى الله عليه وآله وسلم បានទទួលព្រះរាជបញ្ជាឲ្យផ្លាស់គ្ហីបឡាស្ហ់ ?

---

## កិច្ចការសិស្ស ១២

ចូរគូសពេលរបស់ស្វ៍ឡាត់នីមួយៗនៅលើរង្វង់មូលនេះ ។




ចូរសរសេរម៉ោងរបស់ស្វ៍ឡាត់នីមួយៗប្រចាំមួយអាទិត្យ



-ពេលថ្ងៃជ្រេ គឺពេលរបស់ស្វ៍ឡាត់ ស្ហ៊ុស្វរ៍ និងស្វ៍ឡាត់ អ៊ាស្ស៍រ ។

-ពេលងងឹតនៃពេលយប់ គឺពេលស្វ៍ឡាត់ ម៉ាក់រីប និង ស្វ៍ឡាត់ អ៊ីស្ហាអ៍ ។

-ពេលមុនថ្ងៃរះ គឺពេលស្វ៍ឡាត់ ហ្វាច់រ៍ ។

អធិប្បាយលំអិតអំពីពេលវេលា៖

១-ស្វ៍ឡាត់ ហ្វាច់រ៍ ។ ចាប់ពីពេលមុនថ្ងៃរះពិតប្រាកដ (ស្ហ៊ុបហ៊្វ ស្វ៍ឌិក) រហូតដល់ពេលថ្ងៃរះ ។

២-ស្វ៍ឡាត់ ស្ហ៊ុស្វរ៍ ។ ចាប់ពីពាក់កណ្ដាលថ្ងៃ (គឺរវាងថ្ងៃជ្រេ និងថ្ងៃលិច) រហូតដល់ពេលដែលអាចបំពេញស្វ៍ឡាត់ ៤ រ៉ក់អ៊ាត់បាន (ស្វ៍ឡាត់ អ៊ាស្ស៍រ) មុនថ្ងៃលិច ។

៣-ស្វ៍ឡាត់ អ៊ាស្ស៍រ ។ ចាប់ពីពេលដែលអាចបំពេញស្វ៍ឡាត់ ៤ រ៉ក់អ៊ាត់បាន (ស្វ៍ឡាត់ ស្ហ៊ុស្វរ៍) ក្រោយពីពាក់កណ្ដាលថ្ងៃ រហូតដល់ថ្ងៃលិច ។

៤-ស្វ៍ឡាត់ ម៉ាក់រីប ។ ចាប់ពីពេលថ្ងៃលិច (គឺអស់ព័ណ៌ក្រហមពីទិសខាងកើត)

រហូតដល់ពេលដែលអាចធ្វើស្ម៏ឡាត់ ៤ រ៉ក់អ៊ាត់បាន (ស្ម៏ឡាត់ អ៊ីស្ហាអ៍) មុនពាក់កណ្ដាលយប់ (រវាងថ្ងៃលិចនិងពេលថ្ងៃរះ) ។

៥-ស្ម៏ឡាត់ អ៊ីស្ហាអ៍ ។ ចាប់ពីពេលដែលអាចធ្វើស្ម៏ឡាត់ ម៉ាក់រីប បាន (គឺស្ម៏ឡាត់ ម៉ាក់រីបទាន់ពេលកំណត់ភ្លាមៗ) រហូតដល់ពាក់កណ្ដាលយប់ ។

សព្វថ្ងៃនេះ គេមានកូនសៀវភៅ ឬតារាងប្រាប់ពេលវេលាបំពេញស្ម៏ឡាត់ ដែលប្រើទិន្នន័យវិទ្យាសាស្រ្តសម្រាប់គណនាយ៉ាងល្អិតល្អន់ ។

អ្នកអាចកត់សម្គាល់ឃើញថា មានបីអំឡុងពេលសម្រាប់បំពេញស្ម៏ឡាត់ ទោះបីយើងមានប្រាំស្ម៏ឡាត់វ៉ាយិបក្នុងមួយថ្ងៃក៏ដោយ ។ នេះពីព្រោះវាជាការប្រសើរបំផុតដែលបំពេញស្ម៏ឡាត់នៅពេល ដែលពេលវេលារបស់វាចូលមកដល់ភ្លាមៗ ។ ព្រោះតែកំណត់ពេលរបស់ស្ម៏ឡាត់ អ៊ាស្ម៉័រ ចូលមកដល់ក្រោយពីបានបំពេញស្ម៏ឡាត់ ស្ហ៊ុស្ហ៍រ រួចភ្លាម បានជាត្រូវបំពេញស្ម៏ឡាត់ អ៊ាស្ម៉័រ ក្រោយស្ម៏ឡាត់ ស្ហ៊ុស្ហ៍រ ។

ដូចគ្នាដែរសម្រាប់ស្ម៏ឡាត់ ម៉ាក់រីប និងស្ម៏ឡាត់ អ៊ីស្ហាអ៍ ។



គេអាចបំពេញស្ម៏ឡាត់ អ៊ីស្ហាអ៍ ក្រោយស្ម៏ឡាត់ ម៉ាក់រីប បាន ។

ដូច្នេះ ស្ម៏ឡាត់ ស្ហ៊ុស្ហ៍រ និង ស្ម៏ឡាត់ អ៊ាស្ម៉័រ នៅក្នុងអំឡុងពេលតែមួយ ឯស្ម៏ឡាត់ ម៉ាក់រីប និង ស្ម៏ឡាត់ អ៊ីស្ហាអ៍ ក៏នៅក្នុងអំឡុងពេលតែមួយដែរ ។ ដោយរាប់អំឡុងពេលរបស់ស្ម៏ឡាត់ ហ្វាជ្ញ័រ បញ្ចូលផង ទាំងអស់មានបីអំឡុងពេលក្នុង ២៤ ម៉ោង ។

ទោះបីអល់ឡោះហ្វ៍عز وجلទុកចន្លោះពេលដ៏យូរឲ្យយើង ដើម្បីបំពេញរាល់ស្ម៏ឡាត់ទាំងនេះក៏ដោយ ក៏យើងត្រូវតែព្យាយាមបំពេញស្ម៏ឡាត់ នៅពេលដែលពេលកំណត់របស់វាមកដល់ភ្លាម (ដើមពេលវេលា=អាវ៉ាល់ អាល់-វ៉ាក់ទូ) ពីព្រោះមិនសមរម្យទេ ដែលយើងបន្ទាយពេលឲ្យស្ទើរតែផុតអំឡុងពេលទើបអរព្រះគុណអល់ឡោះហ្វ៍ ដែលព្រះអង្គបានប្រោសប្រណីយើងគ្រប់វិស័យ ។

បរទេស - គ្ុំរីប អាល់-គ្ុរបា)

៣) ស៊ីយ៉ារ៉ត្ុំ អ៊ីម៉ាំ មូហ្ាំម៉ាដ្ុំ អាល់-ម៉ាស្ុំឌី صلوات الله عليه والسلام ព្រោះព្រះអង្គជាអ៊ីម៉ាំរបស់សម័យកាលយើង ។

## ស៊ីយ៉ារ៉ត្ុំ អ៊ីម៉ាំ ហ៊្ូសែន៍ صلوات الله عليه والسلام

اَلسَّلامُ عَلَيْكَ يا اَبا عَبْدِ اللّٰهِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱ អាបា អ៊ាប់ឌ៊ិលឡាស្ុំ

اَلسَّلامُ عَلَيْكَ يَا بْنَ رَسُولِ اللّٰهِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱបុត្ររបស់ព្រះសាស្តាអល់ឡោះហ្វ

اَلسَّلامُ عَلَيْكَ يَابْنَ اَميرِ الْمُؤْمِنيْنَ وَابْنَ سَيِّدِ الْوَصِيّيْنَ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱបុត្ររបស់ព្រះអគ្គមហាប្រមុខរបស់បណ្តា អ្នកមានសទ្ធា និងព្រះអគ្គមហាប្រមុខរបស់បណ្តាអ្នកស្នង

اَلسَّلامُ عَلَيْكَ يَابْنَ فاطِمَةَ الزَّهْرَاءِ سَيِّدَةِ نِسَآءِ



| | ចន្ទ | អង្គារ | ពុធ | ព្រហស្បត្តិ៍ | សុក្រ | សៅរ៍ | អាទិត្យ |
|---|---|---|---|---|---|---|---|
| ហ្វាជ្ុំរ៍ | | | | | | | |
| ស៊្ុហ្ុរ៍ | | | | | | | |
| អ៊ាស្ុំរ៍ | | | | | | | |
| ម៉ាក់រីប | | | | | | | |
| អ៊ីស្ាអ៊ុំ | | | | | | | |

**មេរៀនទី ១៣**

# តាក់គីបាត់ - តាស់ប៊ិះហ្ - ស៊ីយ៉ារ៉ត់

តាក់គីបាត់ (تعقيبات) គឺការសូត្រគួរអាន ឌូអាអ៊័ និង ស៊ីយ៉ារ៉ត់ (زيارة) ក្រោយស្ហ៊ឡាត់រួច ។

តាស់ប៊ិះហ្ (تسبيح) ដែលយើងសូត្រក្រោយស្ហ៊ឡាត់រួចជាតាស់ប៊ិះហ្ដែលគេស្គាល់ ថាជាតាស់ប៊ិះហ្របស់ប៊ីប៊ីហ្វាទិម៉ាស់ អាស់-ស្ហាស់រ៉អ៊័ سلام الله عليها ព្រោះព្រះនាងបានទទួលជាអំណោយមកពីព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم ព្រះបិតាព្រះនាង سلام الله عليها ។

ស្ហ៊ឡាត់ជាផ្កាស្អាតមួយទង ឯតាស់ប៊ិះហ្របស់ប៊ីប៊ីហ្វាទិម៉ាស់ អាស់-ស្ហាស់រ៉អ៊័ سلام الله عليها ធ្វើឲ្យផ្កាមួយទងនេះមានក្លិនក្រអូប ។

ដូច្នេះ ក្រោយរាល់ស្ហ៊ឡាត់យើងគប្បីសូត្រតាស់ប៊ិះហ្ព្រោះយើងចង់ឲ្យស្ហ៊ឡាត់យើងដូចផ្កាដែលមានក្លិនក្រអូបដែរ ។



តាស់ប៊ិះហ្របស់ប៊ីប៊ីហ្វាទិម៉ាស់ អាស់-ស្ហាស់រ៉អ៊័ سلام الله عليها គឺ៖

-اَللّٰهُ اَكْبَرُ (អល់ឡោះហ្ទ្រង់មហាធំថ្កើង) ៣៤ ដង ។

-اَلْحَمْدُ لِلّٰهِ (សូមថ្វាយសេចក្ដីសរសើរចំពោះអល់ឡោះហ្) ៣៣ ដង

-سُبْحَانَ اللّٰهِ (សូមថ្វាយសេចក្ដីរុងរឿងចំពោះអល់ឡោះហ្) ៣៣ ដង

បន្ទាប់មក អ្នកគប្បីស៊ូយ៉ូដមួយដងដើម្បីអរព្រះគុណអល់ឡោះហ្ដែលព្រះអង្គបានប្រទានអ្វីៗ ឲ្យអ្នកនិងដើម្បីថ្វាយព្រះអង្គនូវសេចក្ដីប៉ងប្រាថ្នារបស់អ្នក ។

នៅទីបញ្ចប់ អ្នកគប្បីងើបឈរដើម្បីសូត្រស៊ីយ៉ារ៉ត់ដែលមានបីប៉ែកគឺ ៖

១) ស៊ីយ៉ារ៉ត់ អ៊ីមុាំ ហ៊្វសៃន៍ صلوات الله عليه والسلام ព្រោះអង្គជាអគ្គមហាប្រមុខនៃបណ្ដាជនលះបង់ជីវិត

២) ស៊ីយ៉ារ៉ត់ អ៊ីមុាំ អ៊ាលី អារ-រីដ៏ صلوات الله عليه والسلام ព្រោះសពព្រះអង្គត្រូវបញ្ចុះឆ្ងាយពីស្រុកព្រះអង្គ (ជនបរទេសក្នុងចំណោមជន

ព្រះអង្គ ។

យើងគប្បីនឹកដល់អ៊ីម៉ាំទាំងអស់عليهم السلام ក្នុងស៊ីយ៉ារ៉ត់ ។ ស៊ីយ៉ារ៉ត់នេះវែងបន្តិច នឹងលើកយកមកបង្រៀនក្នុងមេរៀនក្រោយ ។



الْعَلَمِيْنَ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱបុត្ររបស់ហ្វាទីម៉ាស់ អាស់-ស្សារ៉អ៊ុ ស្ត្រីឯកលើភពផែនដែនចក្រវាលទាំងពួង

اَلسَّلَامُ عَلٰى الْحُسَيْنِ وَ عَلٰى عَلِيِّ بْنَ الْحُسَيْنِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱហ៊្វសែន៍ និងដល់អាលី បុត្ររបស់ហ៊្វសែន៍

وَ عَلٰى اَوْلَادِ الْحُسَيْنِ وَ عَلٰى اَصْحَابِ الْحُسَيْنِ

និងដល់បណ្តារាជបុត្ររបស់ហ៊្វសែន៍ និងដល់បណ្តាកនរបស់ហ៊្វសែន៍

جَمِيْعًا وَ رَحْمَةُ اللهِ وَ بَرَكَاتُهُ

ទាំងអស់គ្នា ព្រមទាំងព្រះពរជ័យរបស់អល់ឡោះហ្វ៍ផងដែរ ។

**ស៊ីយ៉ារ៉ត់ អ៊ីម៉ាំ អាលី អារ-រីដ៏** صلوات الله عليه والسلام

السَّلامُ عَلَيْكَ يَا مَوْلَايَ وَابْنَ مَوْلَايَ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះអគ្គមហា

ប្រមុខរបស់ទូលបង្គំ រាជបុត្ររបស់ព្រះអគ្គមហាប្រមុខ
របស់ទូលបង្គំ

السَّلامُ عَلَيْكَ يَا غَرِيْبَ الْغُرَبَاء

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱបុរសបរទេសក្នុង
ចំណោមជនបរទេស

السَّلامُ عَلَيْكَ يَا سُلْطَانَ اَبَالْحَسَنِ عَلِيَّ بْنَ مُوْسَ الرِّضَا

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះអគ្គមគ្គទេសក៍
របស់ទូលបង្គំ អាប៊ុល ហ៊ាសាន់ អាលី អារ-រីដ្ហ៍ រាជបុត្រ
របស់មូសា

كُنْ شَفِيْعَنَا وَ شَفِيْعَا وَالِدَيْنَا فِيْ يَوْمِ الْجَزَاءِ

សូមព្រះអង្គជួយធ្វើអន្តរាគមន៍ឲ្យអស់ទូលបង្គំ និងឲ្យមាតា
បិតាអស់ទូលបង្គំផង នាថ្ងៃជំនុំជម្រះ

وَرَحْمَةُ اللهِ وَ بَرَكَاتُهُ

សូមឲ្យពរជ័យនិងសិរីមង្គលរបស់អល់ឡោះហ្វ៍កើតមានដល់
ព្រះអង្គ ។

**ស៊ីយ៉ារ៉ត់ អ៊ីមុាំ មូហាំម៉ាត់ អាល់-ម៉ាស់ឌី** صلوات الله عليه والسلام



السَّلامُ عَلَيْكَ يَابْنَ الْحَسَنِ يَا □ٰاحِبَ الْعَصْرِ وَالزَّمَانِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱរាជបុត្ររបស់
អាល់-ហ៊ាសាន់ ឱម្ចាស់សម័យកាលនិងម្ចាស់ពេលវេលា

السَّلامُ عَلَيْكَ يَا خَلِيْفَةَ الرَّحْمَانِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱបុគ្គលដែលព្រះដ៏
មានព្រះមេត្តាធមិបាន ជ្រើសរើស (អល់ឡោះហ្វ៍)

السَّلامُ عَلَيْكَ يَا شَرِيْكَ الْقُرْآنِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱដៃគូរបស់គួរអាន

السَّلامُ عَلَيْكَ يَا كَعْبَةَ الْاِيْمَانِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱកាក់បាស់នៃជំនឿ

السَّلامُ عَلَيْكَ يَا اِمَامَ الْاِنْسِ وَ الْجِنِّ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱអ៊ីមុាំរបស់មនុស្ស
និងយ៉ិន

وَرَحْمَةُ اللهِ وَ بَرَكَاتُهُ

សូមឲ្យពរជ័យនិងសិរីមង្គលរបស់អល់ឡោះហ្វ៍កើតមានដល់

ប្រសិនបើក្រោយពីបានយកទឹកវូឌ្ហុអ៍ហើយ អ្នកដេកលក់ វូឌ្ហុអ៍របស់អ្នកត្រូវខូច ។
ឧទាហរណ៍ ប្រសិនបើអ្នកចូលដំណេកក្រោយពីបានយកទឹកវូឌ្ហុអ៍ តែវូឌ្ហុអ៍របស់អ្នកត្រូវខូចចាប់ពីពេលដែលអ្នកដេកលក់មិនដឹងខ្លួន ។ អ្នកមិនអាចបំពេញស្វ៏ឡាត់ ហ្វាជ់រ៍ បានទេដោយឥតយកទឹកវូឌ្ហុអ៍សាថ្មី ។

៤) បាត់ស្មារតី

ប្រសិនបើក្រោយពីបានយកទឹកវូឌ្ហុអ៍ហើយ អ្នកបាត់បង់ស្មារតី (សន្លប់) វូឌ្ហុអ៍របស់អ្នកត្រូវខូច ។



**កិច្ចការសិស្ស ១៣**

តើតាក់គ្ជីបាត់ុមានន័យថាអ្វី

____________________________________________

____________________________________________

ចូរផាត់ព័ណ៌លើរូបត៉្លីប និងត៉្លីបាស់ុកំពុងឈរស្វូត្រស៊ីយ៉ារ័ត់ុ



ស៊ីយ៉ារ័ត់ុដែលអ្នកបានរៀនមាន ៣ ប៉ែក ។ តើមានប៉ែកអ្វីខ្លះ (ឈ្មោះស៊ីយ៉ារ័ត់ុ) ?

ចូរទន្ទេញស៊ុីយ៉ារ៉ត្តនេះឲ្យចាំ ហើយព្យាយាមសូត្រស៊ុីយ៉ារ៉ត្តនោះក្នុងពេលសូឡាត្ត ។



**មេរៀនទី ១៤**

# អ្វីដែលធ្វើឲ្យខូចវូឌុអ៍

ទង្វើមួយចំនួនដែលធ្វើឲ្យវូឌុអ៍ខូច (មោឃ:) មាន ៖

១) បត់ជើងតូច បត់ជើងធំ

ប្រសិនបើក្រោយពីបានយកទឹកវូឌុអ៍ហើយ អ្នកទៅបន្ទប់ទឹកដើម្បីបត់ជើងតូច ឬបត់ជើងធំ វូឌុអ៍របស់អ្នកត្រូវខូច (បាទិ្ទល باطل) ហើយអ្នកចាំបាច់ត្រូវតែយកទឹកវូឌុអ៍សាថ្មី ។

២) ពេលដើរខ្យល់ (ដោម)

ប្រសិនបើក្រោយពីបានយកទឹកវូឌុអ៍ហើយ អ្នកដើរខ្យល់ (ដោម) វូឌុអ៍របស់អ្នកត្រូវខូច ។

៣) ដេកលក់

## កិច្ចការសិស្ស ១៥

ត្ត៍លីបកំពុងតែបំពេញស្ទ៍ឡាត្ត៍ តើត្ត៍លីបមិនត្រូវធ្វើអ្វីខ្លះ ដើម្បីនឹងកុំឲ្យខូចស្ទ៍ឡាត្ត៍ ?

___

___

___

___



## កិច្ចការសិស្ស ១៤

ត្ត៍លិបកំពុងតែយកទឹកក្រូឌ្ឋុអ៊ុ៍ តើត្ត៍លិបត្រូវចៀសវាងទង្វើណាដើម្បីកុំឲ្យខូចក្រូឌ្ឋុអ៊ុ៍ ?

___

___

___

___

**មេរៀនទី ១៥**

# ទង្វើដែលបណ្តាលឲ្យខូចស្វ៏ឡាត្ហ់

ទង្វើមួយចំនួនដែលបណ្តាលឲ្យខូចស្វ៏ឡាត្ហ់ (ធ្វើឲ្យស្វ៏ឡាត្ហ់បាទ្វិល) មាន ៖

១- ទង្វើទាំងអស់ដែលធ្វើឲ្យខូចវូឌ្ហុ៍ ។ ពោលគឺ បត់ជើងតូច បត់ជើងធំ ដើរខ្យល់ ដេកលក់ បាត់បង់ ស្មារតី ។ល ។

២- បែរចេញពីគ្ហីបឡាស្ហ់ (លើសពី ៤៥ ដឺក្រេ) ។ ប្រសិនបើបែរចេញពីគ្ហីបឡាស្ហ់ដោយចេតនា ឬដោយអចេតនា (ឧទាហរណ៍ ត្រូវខ្យល់បក់បោក) ស្វ៏ឡាត្ហ់ត្រូវខូច ។

៣- បរិភោគ និង ផឹក

៤- និយាយ ។ លើកលែងតែឆ្លើយតបសាឡាមដោយពាក្យថាសាឡាមដូចគ្នា (អាស់សាឡាមូ អ៊ុឡៃគុម)



៥- សើច (មិនមែនញញឹម)

៦- យំដោយសារអ្វីម្យ៉ាងដែលទាក់ទងនឹងជីវិតរស់នៅ

៧- គ្រប់ទង្វើដែលសន្មត់បានថា យើងមិនកំពុងតែបំពេញស្វ៏ឡាត្ហ់ទេ (ឧទាហរណ៍ ទេះដៃ លោត ។ល ។)

៨- ឱបដៃដោយចេតនា

៩- ថា "អាមីន" ពេលសូត្រស៊ូរ៉ោះត្ហ៍ អាល់-ហ្វាទីហ្ហាស្ហ់ ចប់

១០- សង្ស័យនៅពេលបំពេញស្វ៏ឡាត្ហ់ ពីររ៉ក់អ៊ាត្ហ់ដំបូង (យើងនឹងអធិប្បាយពិស្តារក្នុងមេរៀនក្រោយ) ។

តើ ត៏ហារ៉ោះត៏ និង ណាយ៉ាសាស់ ខុសគ្នាត្រង់ណា ?

______________________________________________

តើវត្ថុណាយ៉ិសអាចធ្វើឲ្យវត្ថុផ្សេងទៀត ទៅជាណាយ៉ិសបានដូចម្តេច ?

______________________________________________



**មេរៀនទី ១៦**

# ត៏ហារ៉ោះត៏ និង ណាយ៉ាសាស់

ត៏ហារ៉ោះត៏ (طهارة) មានន័យថា ភាពបរិសុទ្ធ (មិនមានន័យជាចាំបាច់ថាស្អាតទេ) ។

ណាយ៉ាសាស់ (نجاسة) មានន័យថា ភាពមិនបរិសុទ្ធ (មិនមានន័យជាចាំបាច់ថាកខ្វក់ទេ) ។

វត្ថុណាយ៉ិសនឹងធ្វើឲ្យវត្ថុឯទៀតណាយ៉ិសដែរ ប្រសិនបើវត្ថុទាំងនោះទទឹកហើយត្រូវវត្ថុណាយ៉ិសប៉ះពាល់ ។

អ្វីដែលអាចធ្វើឲ្យរបស់ដែលណាយ៉ិស ទៅជាត៏ហៀរបាន (គឺបរិសុទ្ធ) គេហៅថា មូតោះហ៊ីរ៉ោះត៏ (مطهرة) ។

វត្ថុមូតោះហ៊ីរ៉ោះត៏គឺ ៖

១-ទឹក

២-ថ្ងៃ

៣-ដី

៤-អ៊ីស្លាម

វត្ថុមួយចំនួនជា "អ៊ែន៍ ណាយ៉្ជិស" ពោលគឺ ណាយ៉្ជីសស្រាប់តាំងពីដើមកំណើតរបស់វាមកម្ល៉េះ គឺ ៖

១-ទឹកនោម និង លាមក

២-ឈាម

៣-បុគ្គលស្លាប់ (សាកសព)

៤-កាហ្សៀរ

៥-ឆ្កែ

៦-ជ្រូក

៧-សុរា



## **កិច្ចការសិស្ស ១៦**

សត្វជ្រូកជា អ៊ែនី ណាយ៉្ជិស ។ តើ អ៊ែនី ណាយ៉្ជិស មានសេចក្ដីថាអ្វី ?

ចូរសរសេរនៅលើរូបសត្វជ្រូក នូវឈ្មោះរបស់ អ៊ែន៍ ណាយ៉្ជិសឯទៀត ។



តើ មូត្ហោះហ្វ៊ីរ៉ោះត្វ៍ មានសេចក្ដីថាអ្វី ?

ចូរឲ្យឈ្មោះវត្ថុមូត្ហោះហ្វ៊ីរ៉ោះត្វ៍ ។

**មេរៀនទី ១៨**

# ហ៊្ញីយ៉ាប់ (សម្រាប់នារី)

នារីប្រើហ៊្ញីយ៉ាប់ដើម្បី ៖

១- ចៀសវាងស្ថានភាពដែលមានជន ណា-ម៉ាស៊្រម (គឺមិនមែនម៉ាស៊្រម) (នៅពេលជួបជុំគ្នា)

២- បើមានជន ណា-ម៉ាស៊្រម នៅជាមួយ មិនត្រូវមើលជននោះដោយមិនចាំបាច់ទេ ហើយមិនត្រូវទាក់ទាញអារម្មណ៍គេមកលើខ្លួនទេ (ដោយនិយាយ ឬ សើចខ្លាំងជាដើម)

៣- គ្របខ្លួន និង សក់

ជន ណា-ម៉ាស៊្រម ជាអ្នកណា ៖

បុរសទូទៅជាជន ណា-ម៉ាស៊្រម លើកលែងតែ ៖

-ឪពុកអ្នក និង ជីតាអ្នក

-បងប្រុសនិងប្អូនប្រុសអ្នកនិងកូនៗ (និងកូនៗរបស់បងប្អូនស្រីអ្នក)



**មេរៀនទី ១៧**

# ស្ហៅម៍

ស្ហៅម៍ (صوم) មានន័យថា តមអាហារ ។ ចៀសវាងធ្វើអំពើដែលបណ្ដាលឲ្យការកាន់ត្រណមដាច់ ឬ ខូចចាប់ពីពេលមុនថ្ងៃរះពិតប្រាកដ (ស៊្ហុបហ៊ុ ស្ហ៍ឌិក្ក) រហូតដល់ពេលម៉ាក់រីប (ថ្ងៃលិច) ។

រ៉ាឃ៊ិបត្រូវកាន់ត្រណមអាហារមួយខែរ៉ាម៉ាដ្ហន ។

ខែរ៉ាម៉ាដ្ហនជាខែពិសិដ្ឋបំផុតក្នុងប្រក្រតិទិនអ៊ីស្លាម ។

មគ្គផលដែលមានក្នុងខែនេះគឺ ៖

១-ព្រះមហាគម្ពីរគួរអាន

២-យប់ អាល់-ក្ហដ្រ៍ (ليلة القدر)

ពេញមួយខែនេះ ទង្វើនីមួយៗ ល្អឬអាក្រក់នឹងធ្ងន់ជាងសព្វដង ។ ដូច្នេះ សូត្រគួរអានជាទង្វើប្រសើរគ្រប់ពេល តែវា

ប្រសើរលើសនោះទៅទៀតក្នុងខែរ៉ម៉ាដូន ។ និយាយកុហក ជាទង្វើអាក្រក់មួយ តែវាជាអំពើអាក្រក់លើសនោះទៅទៀត ក្នុងខែរ៉ម៉ាដូន ។

ស្ងៅម៍ មិនមានន័យថាស៊ូអត់បាយនិងអត់ទឹកពេលថ្ងៃនោះទេ គឺមានន័យថាហាមខ្លួនឯងប្រព្រឹត្តគ្រប់អំពើដែលត្រូវហាមព្រមនឹងអត់អាហារ ។

ស្ងៅម៍ អាចធ្វើឲ្យអ្នក ៖
១-មានឆន្ទៈកាន់តែមាំឡើង
២-គិតថាអ្នកដទៃមិនមានសំណាងស្មើខ្លួនអ្នកទេ
៣-នឹកដល់អល់ឡោះហ្វ៍ញឹកញយក្នុងពេលថ្ងៃ
៤-លាងសម្អាតពោះរបស់អ្នក
៥-ផ្លាស់ប្តូររបៀបរស់នៅរបស់អ្នក ឲ្យដូចមុស្លីមពិតប្រាកដ ។



# កិច្ចការសិស្ស ១៧

តើស្ងៅម៍នាំមកឲ្យអ្នកនូវអត្ថប្រយោជន៍អ្វីខ្លះ ?

____________________________________
____________________________________
____________________________________
____________________________________
____________________________________

តើស្ងៅម៍មានន័យថាអ្វី ? តើស៊ូទ្រាំអត់អាហារតែមួយមុខ ឬទេ ?

__________________________________________________
____________________________________

តើគេកាន់ត្រណមស្ងៅម៍ពីពេលណាដល់ពេលណា ?

__________________________________________________
______

តើនៅក្នុងខែណាដែលការកាន់ត្រណមស្ងៅម៍នោះ ជាវ៉ាយិ៊ប ?

__________________________________________________

តើមគ្គផលធំជាងគេក្នុងខែនេះគឺអ្វី ?

__________________________________________________

-បងប្អូនប្រុសរបស់ឪពុកអ្នក (ឪពុកមា ឪពុកធំ ខាងឪពុក)
-បងប្អូនប្រុសរបស់ម្តាយអ្នក (ឪពុកមា ឪពុកធំ ខាងម្តាយ)
-ស្វាមីអ្នក កូនៗរបស់គាត់និងឪពុកគាត់
-កូនៗរបស់អ្នក (បើអ្នកជាយាយ ចៅៗរបស់អ្នកផងដែរ)

ពាក់ហ៊ីយ៉ាប់ជាវ៉ាយិុបសម្រាប់ស្ត្រីគ្រប់រូប ចាប់ពីអាយុ ៩ ឆ្នាំឡើងទៅ ។

ហ៊ីយ៉ាប់មិនមានន័យថាបិទបាំងតែសក់ទេ តែបិបាំងដងខ្លួនអ្នកផងដែរ ។ បានសេចក្តីថា មិនអនុញ្ញាតឲ្យបង្ហាញទ្រង់ទ្រាយខ្លួនរបស់អ្នកទេ (ទ្រង់ទ្រាយស្គម ឬ ធាត់) ។

សាសនាអ៊ីស្លាមឲ្យយើងបិទបាំងខ្លួន ពីព្រោះក្នុងសាសនាអ៊ីស្លាមគេទុកស្ត្រីជាទ្រព្យសម្បត្តិដែលល្អ ។

យើងទុកទ្រព្យសម្បត្តិដែលមានតម្លៃរបស់យើង នៅងកន្លែងដែលមានសុវត្ថិភាពនិង បិទបាំងដើម្បីការពារការឆក់លួច ។ ដូច្នេះហើយបានជាត្រូវការពារសម្រស់ស្ត្រី ។

# កិច្ចការសិស្ស ១៨

តើស្ត្រីប្រើហ៊្វីយ៉ាប់ដើម្បីអ្វី ?

តើអ្នកណាជាជនម៉ាស៊ូវមែសម្រាប់អ្នក ?

ចូរគូររូបសំលៀកបំពាក់ដែលគួរឲ្យពេញចិត្ត និងដែលដូចហ៊្វីយ៉ាប់ ។